

# ផែនការបង្រៀនអំពីការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស សម្រាប់អំណានថ្នាក់ដំបូង


បង្កើតដោយ:

អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា



ផ្តល់មូលនិធិដោយ:

អង្គការ All Children Reading

USAID FROM THE AMERICAN PEOPLE

World Vision Building a better world for children

Australian Aid



Kampuchean Action for Primary Education, Kampong Cham Town, Kampong Cham Province, #56 National Highway 7, Cambodia website: www.kapekh.org email: kape@kapekh.org

| | មាតិកា | |
|---|---|---|
| ១. | **សេចក្តីផ្តើម**<br>១.១ ទិដ្ឋភាពទូទៅ<br>១.២ គោលបំណង និងខ្លឹមសារសំខាន់ៗ<br>១.៣ ការអនុវត្តការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សនៅកម្ពុជា | 1 |
| ២. | **សេចក្តីណែនាំប្រើប្រាស់ឯកសារនេះ** | 5 |
| ៣. | **ផែនការបង្រៀនសម្រាប់គ្រូឧទ្ទេស** | 7 |
| | ផ្នែកទី១: ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស<br>ប្រធានបទ ៣.១: គោលការណ៍មូលដ្ឋាន និងធាតុសំខាន់ៗនៃការបង្រៀនឆ្លើយនឹងតម្រូវសិស្ស<br>ប្រធានបទ ៣.២: ការប្រើប្រាស់ប្រវត្តិទិន្នន័យសិស្សដើម្បីកែលម្អផែនការបង្រៀន<br>ប្រធានបទ ៣.៣: ការរៀបក្រុមសិស្ស និងហានិភ័យដែលត្រូវជៀសវាង | 8<br>16<br>22 |
| | ផ្នែកទី២: ការគ្រប់គ្រងថ្នាក់រៀន<br>ប្រធានបទ ៣.៤: ការរៀបចំថ្នាក់រៀន ការគ្រប់គ្រងពេលវេលា និងការធ្វើផែនការមេរៀន | 28 |
| | ផ្នែកទី៣: ការវាយតម្លៃថ្នាក់រៀន<br>ប្រធានបទ ៣.៥: ការប្រើប្រាស់ស្តង់ដាអំណានដើម្បីលើកកម្ពស់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស<br>ប្រធានបទ ៣.៦: ការកត់ត្រាតាមដានសិស្សដើម្បីតម្លើងកម្រិត | 34 |
| | ផ្នែកទី៤: សម្ភារៈដើម្បីលើកកម្ពស់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស<br>ប្រធានបទ ៣.៧: សម្ភារៈសិក្សាតាមកម្រិតសមត្ថភាព/សម្ភារៈស្វ័យសិក្សា<br>ប្រធានបទ ៣.៨: ការប្រើប្រាស់សៀវភៅអេឡិចត្រូនិចសម្រាប់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស | |
| ៤ | **ឯកសារចែកសម្រាប់សិក្ខាកាម** | 45 |

| | | |
|---|---|---|
| | ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស | |
| ១ | ឯកសារចែក ៣.១.១: ការស្ទង់មតិសិក្ខាកាម | 46 |
| ២ | ឯកសារចែក ៣.១.២: គោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស | 48 |
| ៣ | ឯកសារចែក ៣.១.៣: និយមន័យពាក្យបច្ចេកទេសសំខាន់ៗមួយចំនួនដែលប្រើប្រាស់ក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស | 49 |
| ៤ | ឯកសារចែក ៣.១.៤: អត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស | 50 |
| ៥ | ឯកសារចែក ៣.២.១: របៀបនៃការរៀន | 52 |
| ៦ | ឯកសារចែក ៣.២.២: ទម្រង់ប្រវត្តិទិន្នន័យសិស្ស | 57 |
| ៧ | ឯកសារចែក ៣.២.៣: ការប្រើប្រាស់ករណីសិក្សាដើម្បីបំពេញប្រវត្តិទិន្នន័យសិស្ស | 75 |
| ៨ | ឯកសារចែក ៣.៣.១: ការបង្រៀនសិស្សដែលមានសមត្ថភាពមធ្យមនៅក្នុងថ្នាក់រៀន | 77 |
| ៩ | ឯកសារចែក ៣.៣.២: ករណីសិក្សា – ការកំណត់ស្លាកសិស្ស និងការរំពឹងទុករបស់គ្រូបង្រៀន | 78 |
| ១០ | ឯកសារ ៣.៣.៣: សេចក្ដីសង្ខេបអំពីពាក្យ និងបញ្ញត្តិសំខាន់ៗក្នុងការរៀបចំក្រុមសិស្សតាមកម្រិតសមត្ថភាព | 79 |
| ១១ | ឯកសារចែក ៣.៣.៤: គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបចំក្រុមសិស្សតាមកម្រិតសមត្ថភាព | 80 |
| ១២ | ឯកសារចែក ៣.៣.៥: សេចក្ដៃណែនាំអំពីការរៀបចំក្រុមតាមកម្រិត | 82 |
| | ការគ្រប់គ្រងថ្នាក់រៀន | |
| ១៣ | ឯកសារចែក ៣.៤.១: សេចក្ដីណែនាំអំពីការគ្រប់គ្រងពេលវេលា | 86 |
| ១៤ | ឯកសារចែក ៣.៤.២: ការស្វែងយល់ពីការរៀបចំថ្នាក់រៀនដែលអាចជួយជំរុញវិធីសាស្ត្របង្រៀន | 89 |
| ១៥ | ឯកសារចែក ៣.៤.៣: សេចក្ដីណែនាំអំពីការរៀបចំថ្នាក់រៀន | 90 |

| | | |
|---|---|---|
| **១៦** | ឯកសារចែក ៣.៤.៤: គំរូប្លង់ថ្នាក់រៀន | **92** |
| **១៧** | ឯកសារចែក ៣.៤.៥: គំរូផែនការបង្រៀនបន្ថែម | **93** |
| **១៨** | ឯកសារចែក ៣.៤.៦: សកម្មភាព និងសម្ភារៈជាក់ស្តែងសម្រាប់ប្រើប្រាស់ជំនួយដល់របៀបរៀនផ្សេងៗ | **99** |
| | ការវាយតម្លៃថ្នាក់រៀន | |
| **១៩** | ឯកសារចែក ៣.៥.១: ការស្វែងយល់ពីមូលហេតុដែលយើងធ្វើការវាយតម្លៃ | **105** |
| **២០** | ឯកសារចែក ៣.៥.២ក: ការស្វែងយល់ពីបំណិនអានសំខាន់ៗ៥ដែលជំរុញឱ្យការអានមានភាពស្ទាត់ជំនាញ | **108** |
| **២១** | ឯកសារចែក ៣.៥.២ខ: ការសង្ខេបបំណិនភាសាដែគគ្រូបដណ្ដាប់នៅក្នុងសៀវភៅស្តង់ដា | **111** |
| **២២** | ឯកសារចែក ៣.៥.៣: ការស្វែងយល់ពីទម្រង់នៃសៀវភៅស្តង់ដាអំណាន | **113** |
| **២៣** | ឯកសារចែក៣.៥.៤: ការប្រើតេស្តវាយតម្លៃក្នុងសៀវភៅស្តង់ដាអំណាន | **115** |
| **២៤** | ឯកសារចែក ៣.៥.៥: បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម | **117** |

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅ

**សេចក្តីទូទៅ៖** សៀវភៅនេះមានគោលបំណងជួយគ្រូឧទ្ទេសទាំងឡាយដែលកំពុងបម្រើការនៅក្នុងគម្រោងអភិវឌ្ឍអប់រំរបស់អង្គការ រដ្ឋាភិបាល ឬសាលារៀនឯកជនក្នុងការបំប៉នគ្រូបង្រៀនឱ្យចេះប្រើប្រាស់គោលការណ៍នៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សក្នុងគោលបំណងកែលម្អលទ្ធផលសិក្សាសិស្ស ។ ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស តម្រូវឱ្យអ្នកអប់រំចេះកែសម្រួលការបង្រៀនរបស់ខ្លួនទៅតាមតម្រូវការបុគ្គលសិស្ស ឬក្រុមសិស្សដែលមានតម្រូវការរៀនបន្ថែម ឬសិស្សដែលមានរបៀបរៀនផ្សេងៗគ្នា ។ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស កើតឡើងបន្ទាប់ពីមានការសង្កេតស្រាវជ្រាវញឹកញាប់ដែលបានរកឃើញថា សិស្សមានរបៀបរៀន ចំណាប់អារម្មណ៍ បញ្ហាផ្សេងៗគ្នា ហើយគ្រូបង្រៀនត្រូវកែសម្រួលការបង្រៀនរបស់ពួកគេទៅតាមតម្រូវការទាំងនេះ ដើម្បីសម្រេចឱ្យបានលទ្ធផលសិក្សាជាទីគាប់ចិត្ត ។ វិធីសាស្ត្រនេះ សមស្របទៅនឹងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាណាស់ ពីព្រោះគ្រូបង្រៀនជាញឹកញាប់ប្រើប្រាស់វិធីបង្រៀនតែមួយបែបនៅក្នុងថ្នាក់រៀន ពោលគឺផ្អែកតែលើសៀវភៅសិក្សាគោលតែមួយមុខ ។



ការពិភាក្សាពីការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សនៅក្នុងឯកសារនេះផ្តោតជាសំខាន់ទៅលើការបង្រៀនអំណានថ្នាក់ដំបូងសម្រាប់សិស្សនៅបឋមសិក្សា និងរបៀបដែលគ្រូបង្រៀនអាចរៀបចំថ្នាក់រៀនឡើងវិញ ឱ្យមានប្រសិទ្ធភាព និងរបៀបរៀនដើម្បីកែលម្អលទ្ធផលសិក្សារបស់កុមារនៅបឋមសិក្សាថ្នាក់ដំបូង ។

**ក្រុមគោលដៅ៖** ក្រុមគោលដៅដែលបានរៀបរាប់ក្នុងឯកសារនេះគឺគ្រូបង្រៀន

នៅបឋមសិក្សាដែលកំពុងបង្រៀនសិស្សថ្នាក់ទី១ ទី២ និងទី៣ ។ ទោះបីយ៉ាងណា ខ្លឹមសារក្នុងកម្មវិធីបំប៉ននេះអាចកែសម្រួលបានយ៉ាងងាយស្រួលឱ្យស្របទៅនឹងគ្រូបង្រៀនដែលបង្រៀននៅកម្រិតថ្នាក់ផ្សេងៗទៀតផងដែរ ។ ឯកសារនេះមានគោលបំណងជួយគ្រូបង្រៀនឱ្យចេះឆ្លើយតបនឹងតម្រូវការរបស់កុមារតូចៗគ្រប់កម្រិតសមត្ថភាព បើទោះជាពួកគេមិនសូវចេះ មានសមត្ថភាពមធ្យម ឬពូកែខ្លាំងក៏ដោយ ។

## ១.២ គោលបំណង និងខ្លឹមសារនៃឯកសារនេះ

**គោលបំណង៖** ឯកសារនេះផលិតឡើងជាប្រភេទឯកសារសម្រាប់គ្រូឧទ្ទេសដើម្បីជួយដល់គ្រូបង្រៀនបឋមសិក្សាឱ្យចេះវិធីសាស្ត្របង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ដើម្បីឈានទៅការកែលម្អលទ្ធផលសិក្សាសិស្សគ្រប់មុខវិជ្ជា ប៉ុន្តែផ្តោតជាពិសេសលើអំណាន ។



**ខ្លឹមសារពាក់ព័ន្ធ៖** ខ្លឹមសារក្នុងឯកសារនេះរៀបចំឡើងដើម្បីឱ្យសម្រេចបាននូវលទ្ធផលទាំងឡាយខាងក្រោម៖

- ការជួយគ្រូបង្រៀនឱ្យយល់ដឹងពីគោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ។
- ការជួយគ្រូបង្រៀនឱ្យចេះចាត់ថែង និងរៀបចំក្រុមសិស្សតាមវិធីមួយខុសពី "ការកំណត់ស្លាក" និង "ការមាក់ងាយ" ព្រមទាំងដាក់កិច្ចការសិស្សប្រកបដោយភាពបត់បែនដែលនាំទៅការរៀបចំក្រុមសិស្សបានងាយស្រួល ។
- ការផ្តល់វិធីសាស្ត្រ និងបច្ចេកទេសជាក់ស្តែងមួយចំនួនក្នុងការជំរុញការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ទៅក្នុងថ្នាក់រៀនប្រទេសកម្ពុជា ដោយផ្តោតជាពិសេសទៅលើតួនាទីនៃការវាយតម្លៃ និងការប្រើប្រាស់ស្តង់ដាអំណានសម្រាប់ការវាយតម្លៃនេះ ។
- ការជួយគ្រូបង្រៀនឱ្យយល់ពីគោលការណ៍ជាក់ស្តែងលើការគ្រប់គ្រងថ្នាក់រៀនដែលជួយសម្រួលដល់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស រួមមានការ

គ្រប់គ្រងពេលវេលា ការធ្វើផែនការមេរៀន និងការរៀបចំទិដ្ឋភាពថ្នាក់រៀនជាក់ស្តែង ។

- ការផ្តល់គោលការណ៍ណែនាំដល់គ្រូបង្រៀនឱ្យចេះប្រើប្រាស់សម្ភារៈកម្មវិធីសិក្សារួមមាន សៀវភៅតាមអេឡិចត្រូនិចតាមកម្រិតសមត្ថភាព និងសម្ភារៈផ្សេងៗទៀតដើម្បីបំពេញបន្ថែមដល់ការប្រើប្រាស់សៀវភៅសិក្សាគោល ។
- ការបង្កើតប្រវត្តិទិន្នន័យសិស្ស និងកំណត់ត្រាតាមដាន ដូច្នេះសិស្សទាំងអស់ត្រូវបានតាមដានគ្រប់ដំណើរការសិក្សារបស់ពួកគេ ។
- ការផ្តល់នូវបញ្ជីកិច្ចការជាក់ស្តែងដល់គ្រូបង្រៀន និងនាយកសាលារៀនសម្រាប់ប្រើប្រាស់នៅពេលត្រឡប់ពីសិក្ខាសាលាទៅកាន់សាលារៀនវិញ ។

## ១.៣ ការអនុវត្តការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សក្នុងប្រទេសកម្ពុជា

ការអនុវត្តគោលការណ៍បង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ទាមទារឱ្យគ្រូបង្រៀនមានទាំងជំនាញ និងទេពកោសល្យ ។ ការអនុវត្តគោលការណ៍ទាំងនេះឱ្យមានប្រសិទ្ធភាពគឺនៅមានបញ្ហាប្រឈម សូម្បីតែគ្រូបង្រៀននៅក្នុងប្រទេសអភិវឌ្ឍក៏ដោយ ។ ដូច្នោះ អ្នកប្រើប្រាស់ឯកសារនេះត្រូវពិចារណាអំពីបរិបទអប់រំ ដែលពួកគេចង់កែលម្អ ។ បរិបទដែលមាន គណៈគ្រប់គ្រងសាលារៀនខ្លាំងពូកែ ផលធៀបសិស្សគ្រូសមស្រប មានសម្ភារៈនិងធនធានអប់រំគ្រប់គ្រាន់ នឹងក្លាយជាបរិស្ថានសមស្របបំផុតមួយសម្រាប់កសាងសមត្ថភាពគ្រូបង្រៀនឱ្យទទួលបានជោគជ័យ ។ ទោះបីជាយ៉ាងណា ជាក់ស្តែងសាលារៀនជាច្រើន ពុំទាន់មានបុរេលក្ខខណ្ឌដើម្បីបម្រើដល់ការប្រើប្រាស់វិធីសាស្រ្តនេះឱ្យមានប្រសិទ្ធភាពនៅឡើយ ។ *ដូច្នោះ វាទាមទារឱ្យគ្រូបង្រៀនចេះជ្រើសរើសសកម្មភាពក្នុងកម្រិតណាមួយយកមកអនុវត្តជាចាំបាច់ ។*



ការអនុវត្តឯកសារនេះត្រូវធ្វើទៅតាមបរិបទដែលស្របទៅនឹងទស្សនវិជ្ជាអភិវឌ្ឍមួយដែលគេ

ហៅថា *ការអភិវឌ្ឍពហុវិធី/ផ្លូវ* ដែលក្នុងនោះសាលារៀនដែលទទួលបានធនធានបញ្ចូលច្រើនតាមសមត្ថភាពរបស់ខ្លួននឹងមានសក្តានុពលក្នុងការប្រើប្រាស់វិធីសាស្ត្រទាំងនេះប្រកបដោយប្រសិទ្ធភាព ។ វិធីសាស្ត្រនេះ នឹងជំរុញឱ្យប្រទេសកម្ពុជាសម្រេចបាននូវស្តង់ដាសិក្សាកម្រិតអតិបរមានៅក្នុងសាលារៀនមួយចំនួន ខណៈដែលសាលារៀនមួយចំនួនទៀតអាចអនុវត្តតាមស្តង់ដាកម្រិតអប្បរមា ។

## ២. សេចក្តីណែនាំប្រើប្រាស់សៀវភៅនេះ

ឯកសារនេះប្រើប្រាស់រូបសញ្ញាមួយចំនួនខាងក្រោមដើម្បីឱ្យវាមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ដល់គ្រូឧទ្ទេស ។ សញ្ញាទាំងនេះ បង្ហាញភ្លាមៗនូវប្រភេទសកម្មភាពដែលត្រូវប្រើប្រាស់ជាមួយសិក្ខាកាមទៅតាមជំហាននីមួយៗក្នុងផែនការបង្រៀន ។

ម៉ោងកំណត់សម្រាប់មេរៀន

ការរៀបចំមុនការបំប៉ន: រូបសញ្ញានេះផ្តល់នូវព័ត៌មានពីរបៀបរៀបចំទីកន្លែងបំប៉នសម្រាប់សកម្មភាពសិក្សា ។ វាក៏ផ្តល់នូវសំណូមពរផ្សេងៗពីរបៀបរៀបចំសម្ភារៈសម្រាប់ធ្វើសកម្មភាព ។

សម្ភារៈត្រូវការ: រូបសញ្ញានេះបង្ហាញពីទិដ្ឋភាពទូទៅពីសម្ភារៈត្រូវការចាំបាច់ ។ ជាទូទៅរូបសញ្ញានេះសម្គាល់ពីសម្ភារៈចាំបាច់មូលដ្ឋានដូចជាប៊ិក ឬក្រដាស ។ សម្ភារៈផ្សេងៗទៀតមានជាប្រភេទឯកសារចែកដែលមានភ្ជាប់នឹងឯកសារបំប៉ននេះ ។ ជួនកាលគ្រូឧទ្ទេសត្រូវបង្កើតសម្ភារៈទាំងនេះបន្ថែមជាពីរច្បាប់ ។

លទ្ធផលសិក្សា: រូបសញ្ញានេះផ្តល់នូវឃ្លាខ្លឹមសារដែលត្រូវសម្រេចឱ្យបាន និងត្រូវធ្វើការវាយតម្លៃនៅចុងបញ្ចប់ផែនការបង្រៀន ។

### រូបសញ្ញាអំពីជំហាន និងដំណើរការ

ផ្នែកទី៣នៃឯកសារនេះផ្តល់នូវផែនការបង្រៀនអំពីរបៀបបំប៉នគ្រូបង្រៀនបឋមសិក្សាដែលត្រូវអនុវត្តបច្ចេកទេសនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស នៅក្នុងថ្នាក់រៀន ។ រូបសញ្ញាខាងក្រោមត្រូវបានប្រើប្រាស់សម្រាប់ណែនាំផែនការបំប៉នជាក់ស្តែង ។ រូបសញ្ញាទាំងនេះនឹងប្រាប់អ្នកសម្របសម្រួលភ្លាមៗពីប្រភេទសកម្មភាពដែលគ្រោងទុកនៅក្នុងផែនការបង្រៀន ។ ផ្នែកនេះក៏ផ្តល់នូវសកម្មភាព សំណួរបំផុស ឧទាហរណ៍បញ្ជាក់បន្ថែមលើលំហាត់ និងកិច្ចការបន្ថែម ។ គ្រូឧទ្ទេសអាចមើលឃើញយ៉ាងងាយស្រួលអំពីអ្វីដែលត្រូវធ្វើតាមរយៈរូបសញ្ញាទាំងនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ្រូឧទ្ទេសត្រូវអានមេរៀនទាំងមូលឱ្យបានច្បាស់ជាមុនសិន ជាពិសេសនៅពេល

ប្រើប្រាស់លើកដំបូង ។



ការធ្វើសកម្មភាព: រូបសញ្ញានេះចង្អុលបង្ហាញថា អ្នកសម្របសម្រួលត្រូវធ្វើសកម្មភាពជាក់ស្តែងដូចជា ផ្តល់ឯកសារចែក រៀបចំតុឡើងវិញ ចាត់ចែងក្រុម ។ល។



ការសួរសំណួរ: រូបសញ្ញានេះប្រាប់អ្នកសម្របសម្រួលឱ្យសួរសំណួរគន្លឹះដល់សិក្ខាកាមដែលជាការចាប់ផ្តើមនៃសកម្មភាព ឬការពិភាក្សា ។



ការពិភាក្សា: រូបសញ្ញានេះបង្ហាញថា អ្នកសម្របសម្រួលត្រូវដឹកនាំការពិភាក្សា ឬ អនុញ្ញាតឱ្យសិក្ខាកាមពិភាក្សាអ្វីមួយក្នុងក្រុមរបស់ពួកគេ ។



កិច្ចការសំណេរ: រូបសញ្ញានេះប្រាប់ថា សិក្ខាកាមត្រូវសរសេរអ្វីមួយនៅលើក្រដាសផ្ទាំង បំពេញលំហាត់ ឬធ្វើកិច្ចការសំណេរផ្សេងៗ ។



សេចក្តីពន្យល់: រូបសញ្ញានេះចង្អុលបង្ហាញថា អ្នកសម្របសម្រួលត្រូវពន្យល់អ្វីមួយទៅសិក្ខាកាម ។

# ៣. ផែនការបំប៉ន

## ផែនការបង្រៀន និងសម្ភារៈសម្រាប់គ្រូឧទ្ទេស

# ផ្នែកទី១៖ ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

## មេរៀន ៣.១ គោលការណ៍មូលដ្ឋាន និងធាតុសំខាន់ៗនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

ចំនួនម៉ោងបង្រៀន: ៩០ នាទី

ការរៀបចំរបស់គ្រូឧទ្ទេស:

- សរសេរលទ្ធផលសិក្សានៃមេរៀនលើក្រដាសផ្ទាំងដើម្បីចាប់ផ្តើមមេរៀន
- ថតចម្លងឯកសារចែក ៣.១.១: *ការស្ទង់មតិសិក្ខាកាម*[1]
- ថតចម្លងឯកសារចែក ៣.១.២: *គោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស*
- ថតចម្លងឯកសារចែក ៣.១.៣: *និយមន័យនៃពាក្យបច្ចេកទេសសំខាន់ៗមួយចំនួនដែលប្រើប្រាស់ជាទូទៅក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស*
- ថតចម្លងឯកសារចែក ៣.១.៤: *អត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស*
- រៀបចំបណ្ណអ៊ុត ត្រូវ-ខុស សម្រាប់សកម្មភាពក្រុម

ធនធាន/សម្ភារៈ:

- ក្រដាសផ្ទាំង ហ្វឺតបារ
- ក្រដាសផ្ទាំងដែលសង្ខេបពីលទ្ធផលសិក្សានៃមេរៀន
- ឯកសារចែក ៣.១.១: ការស្ទង់មតិសិក្ខាកាម
- ឯកសារចែក ៣.១.២: គោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹង

[1] ការស្ទង់មតិនេះអាចធ្វើបែបអេឡិចត្រូនិចក៏បាន បើសិនជាមានថាប្លេតគ្រប់គ្រាន់

តម្រូវការសិស្ស

- ឯកសារចែក ៣.១.៣: និយមន័យនៃពាក្យបច្ចេកទេសសំខាន់ៗមួយចំនួនដែលប្រើប្រាស់ជាទូទៅក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស
- ឯកសារចែក ៣.១.៤: អត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស
- បណ្ណអ៊ុត ត្រូវ-ខុស (មួយឈុត សម្រាប់មួយក្រុម)
- ថាប្លេត (បើសិនជាកម្រងសំណួរត្រូវបានធ្វើជាអេឡិចត្រូនិច)

លទ្ធផលសិក្សា:

- សិក្ខាកាមអាច**ពន្យល់**ពីគោលការណ៍សំខាន់ៗនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ជាពិសេសទំនាក់ទំនងរវាងការវាយតម្លៃសិស្ស និងនិងការបង្រៀន
- សិក្ខាកាមអាច**កំណត់និយមន័យ**ពាក្យសំខាន់ៗដែលប្រើប្រាស់ក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ដូចជា ភាពខ្លាំង តម្រូវការ ចំណូលចិត្ត ចំណាប់អារម្មណ៍ ។ល។
- សិក្ខាកាមអាច**បង្ហាញភាពខុសគ្នា**រវាងបញ្ញតសំខាន់ៗដែលមានអត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវទាក់ទងនឹងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស។

## ជំហានក្នុងការបំប៉ន

### លទ្ធផលសិក្សា

សូមបិតក្រដាសផ្ទាំងនៅលើក្តារខៀនដែលសង្ខេបពីលទ្ធផលសិក្សាសម្រាប់មេរៀន ។ ពន្យល់ពីលទ្ធផលសិក្សាទាំងនោះ និងបញ្ជាក់ថានេះគឺជាអ្វីដែលសិក្ខាកាមគួរតែអាចធ្វើបាននៅពេលបញ្ចប់មេរៀននេះ ។

### ការស្វែងរកអ្វីដែលសិក្ខាកាមដឹងអំពីការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

សូមហុចទម្រង់ស្ទង់មតិឱ្យសិក្ខាកាម (ឯកសារចែក ៣.១.១) និងពន្យល់ថាឯកសារនេះនឹងជួយគ្រូឧទ្ទេសយល់ដឹងកាន់តែច្បាស់ពីមតិយោបល់របស់សិក្ខាកាមទាក់ទងនឹងគោលការណ៍សំខាន់ៗនៃការបង្រៀនឆ្លើយតបតម្រូវការសិស្ស និងរបៀបដែលពួកគេបង្រៀនជាទូទៅ ។

ឱ្យសិក្ខាកាមពិនិត្យសំណួរទាំង៦នៅក្នុងទម្រង់ស្ទង់មតិ រួចឆ្លើយ ។ ផ្តល់ពេលឱ្យសិក្ខាកាមប្រហែល១០នាទីដើម្បីបំពេញទម្រង់ស្ទង់មតិនេះ ។

***សម្គាល់***: *បើសិនទម្រង់ស្ទង់មតិនេះត្រូវបានធ្វើជាអេឡិចត្រូនិច នោះអ្នកសម្របសម្រួលអាចផ្តល់ចម្លើយភ្លាមដោយបញ្ចាំងតាម LCD ។ បើសិនជាមិនមាន សុំឱ្យអ្នកជំនួយការវិភាគលទ្ធផលទាំងនេះ រួចហើយបង្ហាញប្រាប់សិក្ខាកាមនៅចុងបញ្ចប់សិក្ខាសាលា ។*

ពេលសិក្ខាកាមបំពេញទម្រង់ស្ទង់មតិចប់ សូមដឹកនាំការពិភាក្សាដោយត្រួតពិនិត្យសំណួរ និងចម្លើយនីមួយៗ ។ សូមបើកចំហរឱ្យមានការផ្តល់យោបល់ចំពោះចម្លើយក្នុងពេលណាមួយបន្ថែមទៀតក្នុងកំឡុងពេលសិក្ខាសាលារហូតដល់ចប់ ។ ទោះបីជាយ៉ាងណា អ្នកសម្របសម្រួលត្រូវចេះ ប្រើប្រាស់សំណួរ និងចម្លើយរបស់សិក្ខាកាម សម្រាប់ធ្វើការពិភាក្សាដែលពាក់ព័ន្ធទៅនឹងគោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ។

## និយមន័យមូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស និងរបៀបដែលវដ្តដំណើរការ

ចាប់ផ្តើមការពិភាក្សាពាក់ព័ន្ធនិយមន័យនៃ*ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស* និងរបៀបដែលវាដំណើរការបែបជាវដ្ត ។ ផ្តល់ឯកសារឯកសារចែក ៣.១.២ *គោលការណ៍មូលដ្ឋាននៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស* ។ ចំណុចសំខាន់ៗដែលអ្នកសម្របសម្រួលត្រូវលើកឡើងរួមមាន៖

- ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្សមានដំណើរការបែបជាវដ្ត ។
- វដ្តចាប់ផ្តើមពីសិស្ស – ពោលគឺគ្រូបង្រៀនត្រូវស្គាល់សិស្សជាមុនសិន
- យើងស្គាល់សិស្សមិនមែនតាមរយៈតែការធ្វើតេស្តមួយមុខប៉ុណ្ណោះទេ ប៉ុន្តែតាមការសង្កេតពី *ភាពត្រៀមជាស្រេច* ដើម្បីរៀនបញ្ញត្តិ និងបំណិនថ្មីៗ

*ចំណាប់អារម្មណ៍* និង *ចំណូលចិត្ត* ។

- តើយើងត្រូវស្គាល់អ្វីខ្លះអំពីសិស្សរបស់យើង?
  - ស្គាល់អំពី ភាពខ្លាំង និងតម្រូវការរបស់សិស្ស
    ឧទា. អាចអានបានស្ទាត់ ប៉ុន្តែយល់ដឹងតិចតួច ស្គាល់តួអក្សរ ប៉ុន្តែពិបាកអានពាក្យ ។ល។
  - ស្គាល់ពី ភាពត្រៀមជាស្រេច របស់សិស្សដើម្បីរៀនបញ្ញត្តិថ្មីៗ
    ឧទា. សិស្សអាចខ្មាសអៀនក្នុងការអានល្បះឱ្យឮៗ ប៉ុន្តែមានចំណូលចិត្តក្នុងការអានស្ងាត់ៗ អាចអានបានពាក្យមួយព្យាង្គ ប៉ុន្តែមិនទាន់អានបានពាក្យដែលមានច្រើនព្យាង្គ សិស្សងាយនឹងបាក់ទឹកចិត្ត និងខ្មាសអៀន ។ល។
  - ស្គាល់ពីចំណាប់អារម្មណ៍របស់សិស្ស
    ឧទា. ចូលចិត្តអានរឿងអំពីសត្វ រីករាយក្នុងការសរសេរ ចូលចិត្តអានកំណាព្យ និងចម្រៀង ។ល។
  - ស្គាល់ពីចំណូលចិត្តរបស់សិស្ស
    ឧទា. ចូលចិត្តធ្វើការម្នាក់ឯង ចូលចិត្តធ្វើការជាដៃគូ ឬក្រុម ចូលចិត្តធ្វើអ្វីមួយដោយការចាប់កាន់ផ្ទាល់ដៃ
- ប្រើប្រាស់យុទ្ធសាស្ត្របង្រៀនខុសៗគ្នាដើម្បីសម្របសម្រួលការបង្រៀនរបស់ខ្លួនទៅតាមអ្វីដែលបានស្គាល់ពីសិស្ស ។ នេះជាចំណុចមួយដែលយើងត្រូវពិភាក្សាលម្អិតបន្ថែមនៅពេលក្រោយ ។
- ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស មិនមែនមានន័យថាជាការបង្រៀនផ្តោតលើបុគ្គលសិស្សនោះទេ ប៉ុន្តែជាអ្វីមួយដែលយើងបានប្តូរការបង្រៀនទៅជាការបង្រៀនសម្រាប់ក្រុមសិស្ស ក្នុងខណៈពេលណាមួយ ។

## ការរៀនអំពីពាក្យសំខាន់ៗដែលប្រើប្រាស់ក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

ក្នុងពេលពិភាក្សាខាងលើ អាចមានពាក្យមួយចំនួនហាក់ដូចជាថ្មីសម្រាប់សិក្ខា

កាម ប៉ុន្តែវាមានសារៈសំខាន់ណាស់ដែលសិក្ខាកាមត្រូវយល់ដឹងក្នុងបរិបទនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ។ ពាក្យទាំងនេះរួមមាន៖

*ភាពខ្លាំង តម្រូវការ ភាពត្រៀមជាស្រេច ចំណាប់អារម្មណ៍ និងចំណូលចិត្ត*

ដើម្បីឱ្យសិក្ខាកាមយល់ដឹងកាន់តែច្បាស់ សូមផ្តល់ឯកសារចែក ៣.១.៣: *និយមន័យពាក្យបច្ចេកទេសសំខាន់ៗមួយចំនួនដែលប្រើប្រាស់ទូទៅនៅក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស* ។ ត្រួតពិនិត្យនិយមន័យពាក្យនីមួយៗដោយផ្តោតជាសំខាន់ទៅលើឧទាហរណ៍ដែលបានផ្តល់ជូន ។

<u>សកម្មភាពក្រុម</u>: បន្ទាប់មក អ្នកសម្របសម្រួលគួរព្យាយាមពង្រឹងការយល់ដឹងសេចក្តីពន្យល់ខាងលើតាមរយៈសកម្មភាពក្រុមដែលតម្រូវឱ្យសិក្ខាកាមធ្វើព្យុះគំនិតរកឧទាហរណ៍ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានសម្រាប់ពាក្យនីមួយៗខាងលើ ។ អ្នកសម្របសម្របអាចឱ្យក្រុមមួយ ពិភាក្សាលើពាក្យមួយ ហើយក្រុមផ្សេងទៀតពិភាក្សាលើពាក្យផ្សេង ។ ម្យ៉ាងទៀត អ្នកសម្របសម្រួលអាចឱ្យក្រុមទាំងអស់ធ្វើព្យុះគំនិតរកឧទាហរណ៍យ៉ាងតិចឱ្យបាន៥សម្រាប់ពាក្យនីមួយៗ ។ សូមផ្តល់ឧទាហរណ៍មួយរួមគ្នាសម្រាប់ពាក្យនីមួយៗមុននឹងអនុញ្ញាតបន្តកិច្ចការនេះ ។ សូមប្រើតារាងខាងក្រោម (ដោយមានឧទាហរណ៍គម្រូមួយចំនួន) ដើម្បីសរសេរចម្លើយចូល៖

| ពាក្យ | ឧទាហរណ៍ |
|---|---|
| ភាពខ្លាំង | • ការស្គាល់តួអក្សរបានច្បាស់<br>• ការសរសេរបានស្អាត<br>• ការអានស្ទាត់<br>• ការអានយល់បានល្អ<br>• បំណិនបកស្រាយ/អានពាក្យបានល្អ<br>• ការសរសេរកំណាព្យ<br>• បំណិនស្តាប់បានល្អ |
| តម្រូវការ | • ការកែលម្អការស្គាល់ព្យញ្ជនៈ<br>• ការកែលម្អការស្គាល់ស្រៈ |

| | |
|---|---|
| | • ការកែលម្អបំណិនបកស្រាយ/អានពាក្យ<br>• ការកែលម្អសមត្ថភាពឱ្យចេះអនុវត្តតាមសេចក្ដីណែនាំរបស់គ្រូ<br>• ការកែលម្អសមត្ថភាពឱ្យចេះអានស្ទាត់ និងមានទំនុកចិត្ត<br>• ការកែលម្អសមត្ថភាពយល់ដឹងអ្វីដែលបានអាន |
| ភាពត្រៀមជាស្រេច | • អាចអានពាក្យមួយៗបាន ប៉ុន្តែលំបាកនៅពេលអានជាល្បះ<br>• អាចអានពាក្យមួយព្យាង្គ ប៉ុន្តែមិនអាចអានពាក្យដែលមានច្រើនព្យាង្គ<br>• អាចអានបានស្ទាត់ ប៉ុន្តែមិនសូវមានបំណិនអានដោយយល់ន័យ<br>• ស្គាល់តួអក្សរ ប៉ុន្តែមិនការលំបាកក្នុងការបកស្រាយ/អានចេញជាពាក្យ<br>• ស្គាល់តួអក្សរ ប៉ុន្តែមិនទាន់ស្គាល់ពីភាពខុសគ្នានៃតួអក្សរពួក អ និង អ៊<br>• អាចសរសេរល្បះបាន ប៉ុន្តែមិនទាន់ចេះសរសេរចេញជាតែងសេចក្ដី<br>• អាចសរសេរពាក្យបាន ប៉ុន្តែមិនទាន់អាចសរសេរតាមអានបាន |
| ចំណាប់អារម្មណ៍<br>(ពោលគឺ អ្វីដែលពួកគេចាប់អារម្មណ៍) | • ចាប់អារម្មណ៍កំណាព្យ<br>• ចាប់អារម្មណ៍រឿងអំពីសត្វ<br>• ចាប់អារម្មណ៍ចូលចិត្តរឿងអំពីអតីតកាល និងរឿងប្រជាប្រិយ<br>• ចាប់អារម្មណ៍សៀវភៅដែលមានរូបភាពច្រើន<br>• ចាប់អារម្មណ៍ច្រៀងចំរៀង<br>• ចាប់អារម្មណ៍និពន្ធរឿង<br>• ចាប់អារម្មណ៍ល្បែងដោះប្រស្នា និងពាក្យ<br>• ចាប់អារម្មណ៍និទានរឿង |
| ចំណូលចិត្ត<br>(ពោលគឺ របៀបដែលសិស្សចូលចិត្តរៀន) | • ចូលចិត្តរៀនជាបុគ្គល<br>• ចូលចិត្តធ្វើការជាដៃគូ<br>• ចូលចិត្តធ្វើការជាក្រុម<br>• ចូលចិត្តធ្វើកិច្ចការដែលប្រើដៃចាប់កាន់ (ឧទា. បណ្ណពាក្យ)<br>• ចូលចិត្តអានស្ងាត់ ជាជាងអានឮ<br>• ចូលចិត្តអានឮ ជាជាងអានស្ងាត់<br>• ចូលចិត្តរៀនតាមការស្ដាប់<br>• ចូលចិត្តរៀននៅកន្លែងណាដែលមានពណ៌ និងរូបភាពច្រើន |

ផ្តល់ពេលឱ្យសិក្ខាកាម១៥នាទី ដើម្បីធ្វើព្យុះគំនិតរកចម្លើយរបស់ពួកគេ និងសរសេរនៅលើក្រដាសផ្ទាំង ។

គ្រូតពិនិត្យចម្លើយក្រុមនីមួយៗជាក្រុមធំ និងពិភាក្សា/កែតម្រូវតាមការចាំបាច់ ។

## ការយល់ដឹងពីអត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

ផ្តល់ឯកសារចែក ៣.១.៤ *អត្ថន័យត្រឹមត្រូវ និងមិនត្រឹមត្រូវនៃការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស* ។ សូមពន្យល់ឱ្យបានលម្អិតពីសេចក្តីថ្លែងនីមួយៗនៅក្នុងឯកសារចែកដោយផ្តោតទៅលើការយល់ខុសមួយចំនួនអំពីការបង្រៀនឆ្លើយតបតម្រូវការសិស្ស (ឧទា. ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស គឺជាការបង្រៀនបែបលក្ខណៈជាបុគ្គល ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស គឺមានន័យថាជាការឱ្យសិស្សធ្វើការជាក្រុមថេរ ។ល។

<u>សកម្មភាពក្រុម</u>: ឱ្យសិក្ខាកាមធ្វើកិច្ចការនេះដោយរៀបសេចក្តីថ្លែងអំពីការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ដោយចំណាត់ថ្នាក់ខុស ឬត្រូវ ។ សូមផ្តល់សេចក្តីថ្លែងដែលបានអ៊ុតមួយឈុត ទៅក្រុមនីមួយៗ ហើយឱ្យពួកគេធ្វើចំណាត់ថ្នាក់សេចក្តីថ្លែងទាំងនោះ ។ សូមប្រើប្រាស់តារាងខាងក្រោមរដើម្បីរៀបសេចក្តីថ្លែងទាំងនេះ៖

*<u>សេចក្តីថ្លែងទី១</u>: ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស មានន័យថាជាការបង្រៀនសិស្សបែបបុគ្គល ។*

*<u>សេចក្តីថ្លែងទី២</u>: ក្រុមសិស្សត្រូវផ្លាស់ប្តូរជានិច្ចដោយអាស្រ័យលើកិច្ចការដែលត្រូវធ្វើ ។*

*<u>សេចក្តីថ្លែងទី៣</u>: សិស្សដែលមានតម្រូវការច្រើនជាង ធ្វើតេស្តដែលមានភាពងាយស្រួលជាង*

*<u>សេចក្តីថ្លែងទី៤</u>: គ្រូបង្រៀនរៀបចំកិច្ចការច្រើនដែលជំរុញឱ្យសិស្សទទួលបានសមត្ថភាពដូចគ្នា ហើយឱ្យសិស្សធ្វើកិច្ចការផ្អែកតាមចំណូលចិត្ត និងភាពត្រៀមជាស្រេចរបស់*

*ពួកគេ ។*

*<u>សេចក្តីថ្លែងទី៥</u>: បរិស្ថានសិក្សាក្នុងថ្នាក់រៀនធ្វើឡើងមិនមានរចនាសម្ព័ន្ធ ដោយគ្មានច្បាប់វិន័យ ឬទម្លាប់ក្នុងការអនុវត្ត ។*

*<u>សេចក្តីថ្លែងទី៦</u>: គ្រូបង្រៀនលើកទឹកចិត្តសិស្សដោយផ្តល់ជម្រើសដល់ពួកគេទាក់ទងនឹងអ្វីដែលពួកគេរៀន ។*

*<u>សេចក្តីថ្លែងទី៧</u>: គ្រូបង្រៀនត្រូវស្គាល់ពីរបៀបដែលសិស្សចូលចិត្តរៀន និងអ្វីដែលពួកគេចាប់អារម្មណ៍ ។.*

*<u>សេចក្តីថ្លែងទី៨</u>: គ្រូបង្រៀនគួរជួបជាមួយសិស្សឱ្យបានញឹកញាប់ និងជាបុគ្គលដើម្បីស្វែងយល់ពីរបៀបដែលពួកគេរៀន និងតម្រូវការរបស់ពួកគេ ។*

| សេចក្តីថ្លែងដែល ត្រូវ | សេចក្តីថ្លែងដែល ខុស |
|---|---|
| • ???<br>• ???<br>• ???<br>• ??? | • ???<br>• ???<br>• ???<br>• ??? |



នៅពេលសិក្ខាកាមបានធ្វើចំណាត់ថ្នាក់សេចក្តីថ្លែង សូមគ្រូតពិនិត្យរួមគ្នាជាក្រុមធំ និងធ្វើការបញ្ជាក់/ពន្យល់បន្ថែមតាមការចាំបាច់ ។

# មេរៀន ៣.២ ការប្រើប្រាស់ប្រវត្តិទិន្នន័យសិស្សដើម្បីកែលម្អផែនការបង្រៀន

ម៉ោងកំណត់: ៩០នាទី

ការរៀបចំរបស់គ្រូឧទ្ទេស:

- សរសេរលទ្ធផលសិក្សានៃមេរៀននៅលើក្រដាសផ្ទាំងដើម្បីចាប់ផ្តើមមេរៀន ។
- ថតចម្លងឯកសារចែក ៣.២.១: *របៀបរៀនរបស់សិស្ស*
- ថតចម្លងឯកសារចែក ៣.២.២: *ទម្រង់ប្រវត្តិទិន្នន័យសិស្ស*
- ថតចម្លងឯកសារចែក ៣.២.៣: *ករណីសិក្សាដើម្បីបំពេញប្រវត្តិទិន្នន័យសិស្ស*
- ថតចម្លងតេស្តអំពី *របៀបរៀនរបស់សិស្ស* (បើសិនជាអ្នកសម្របសម្រួលសម្រេចចិត្តមិនធ្វើតាមអេឡិចត្រូនិច)

ធនធាន/សម្ភារ:

- ក្រដាសផ្ទាំង ហ្វឺតបារ
- ក្រដាសផ្ទាំងដែលសង្ខេបអំពីលទ្ធផលសិក្សានៃមេរៀន
- ឯកសារចែក ៣.២.១: របៀបរៀនរបស់សិស្ស
- ឯកសារចែក ៣.២.២: ទម្រង់ប្រវត្តិទិន្នន័យសិស្ស
- ឯកសារចែក ៣.២.៣: ករណីសិក្សាដើម្បីបំពេញប្រវត្តិទិន្នន័យសិស្ស
- ថាប្លេត (បើសិនជារបៀបរៀនរបស់សិស្សត្រូវបានធ្វើតាមអេឡិចត្រូនិច – សូមមើលតំណភ្ជាប់ខាងក្រោម៖

  ភាសាអង់គ្លេស: ។

  ភាសាខ្មែរ: http://kapekh.org/?p=whatwedo&id=21&l=Khmer#learningstyle

លទ្ធផលសិក្សា:

- សិក្ខាកាមអាច**ពន្យល់**ពីភាពខុសគ្នានៃសិស្សទាក់ទងនឹងរបៀបរៀន ចំណាប់អារម្មណ៍ ភាពខ្លាំង និងភាពខ្សោយ ។
- សិក្ខាកាមអាច**កំណត់**ពីរបៀបរៀនផ្សេងៗ តាមរយៈករណីសិក្សាខ្លីមួយក្នុងឯកសារ ៣.២.១ ។
- សិក្ខាកាមអាច**ពន្យល់**ពីគោលបំណងនៃការប្រើប្រាស់ប្រវត្តិទិន្នន័យសិស្ស ។
- សិក្ខាកាមអាចផ្លាស់ប្តូរព័ត៌មានដែលមានក្នុងករណីសិក្សាអំពីសិស្សម្នាក់ទៅជាប្រវត្តិទិន្នន័យដែលពិពណ៌នាពីសិស្សនោះ ដោយប្រើប្រាស់ទម្រង់ប្រវត្តិទិន្នន័យសិស្សក្នុងឯកសារ ៣.២.២ ។

## ជំហាននៃការបំប៉ន

លទ្ធផលសិក្សា

បិតក្រដាសផ្ទាំងនៅលើក្តារខៀនដែលសង្ខេបអំពីលទ្ធផលសិក្សាសម្រាប់មេរៀន ។ សូមពន្យល់លទ្ធផលសិក្សា និងបញ្ជាក់ថា នេះគឺជាអ្វីមួយដែលសិក្ខាកាមគួរតែអាចធ្វើបាននៅពេលបញ្ចប់មេរៀន ។




របៀបដែលសិស្សមានភាពខុសគ្នាទាក់ទងនឹងការរៀន

ដើម្បីកសាងចំណេះដឹងបន្ថែមលើការបង្រៀនខាងដើមដល់សិក្ខាកាម អ្នកសម្របសម្រួលគួរត្រួតពិនិត្យឡើងវិញពីសារៈសំខាន់នៃការយល់ដឹងពីភាពខុសគ្នារវាងសិស្សម្នាក់ៗ ជាពិសេសពាក់ព័ន្ធនឹងអ្វីដែលគេហៅថា "របៀបរៀន" ។ សិក្ខាកាមគួរឆ្លើយថាសិស្សមានភាពខុសគ្នាទងទងនឹង ភាពខ្លាំង/ភាពខ្សោយ ចំណាប់អារម្មណ៍ ចំណូលចិត្តរៀន ។ល។ គំនិតសំខាន់ដែលត្រូវលើកឡើងនៅទីនេះម្តងទៀតគឺថា៖

*ការដឹងពីភាពខុសគ្នារវាងសិស្សម្នាក់ៗ នឹងជួយឱ្យគ្រូបង្រៀនអាចសម្របសម្រួលការបង្រៀនរបស់ខ្លួនទៅតាមចំណូលចិត្តរៀនរបស់សិស្ស ។*

បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឯកសារចែក ៣.២.១ ឱ្យសិក្ខាកាមទាំងអស់ និងត្រួតពិនិត្យរបៀបរៀននីមួយៗ៖ (i) ការរៀនតាមការធ្វើចលនា; (ii) ការរៀនតាមការមើលឃើញ; (iii) ការរៀនតាមការស្តាប់និងនិយាយ; (iv) ការចូលចិត្តរៀនតែពីខ្លួនឯង និង (v) ការចូលចិត្តរៀនពីក្រុម ។ សូមផ្តល់ឧទាហរណ៍ពីរបៀបរៀននីមួយៗ ហើយបញ្ជាក់ថាគ្រប់គ្នាអាចមានរបៀបរៀនច្រើនបែប ប៉ុន្តែជាធម្មតាមនុស្សម្នាក់ៗមានតែរបៀបរៀនមួយឬពីរប៉ុណ្ណោះដែលលេចធ្លោជាងគេ ។

បន្ទាប់ពីមើលឯកសារចែកចប់ ឱ្យសិក្ខាកាមវាយតម្លៃរបៀបរៀនរបស់ខ្លួនដោយធ្វើតេស្តរបៀបរៀនជាអេឡិចត្រូនិចតាមតំណភ្ជាប់: http://kapekh.org/?p=whatwedo&id=21&l=Khmer#learningstyle. សូមប្រគល់ថាប្លេតឱ្យសិក្ខាកាមម្នាក់មួយហើយចូលទៅកាន់តំណភ្ជាប់ខាងលើ ។ ផ្តល់ពេល១០នាទីឱ្យសិក្ខាកាមសម្រាប់ធ្វើលំហាត់នេះ ។ នៅពេលសិក្ខាកាមបានធ្វើតេស្តចប់ សូមសួរពួកគេអំពីពិន្ទុ និងសរសេរពិន្ទុទាំងនោះនៅលើក្តារខៀន ។

- តើមានប៉ុន្មាននាក់ដែលមាន*របៀបរៀនបែបចលនា* លេចធ្លោជាងរបៀបរៀនផ្សេងៗទៀត? _____%
- តើមានប៉ុន្មាននាក់ដែលមាន*របៀបរៀនតាមការមើល* លេចធ្លោជាងរបៀបរៀនផ្សេងៗទៀត? _____%
- តើមានប៉ុន្មាននាក់ដែលមាន*របៀបរៀនតាមការស្តាប់និងនិយាយ* លេចធ្លោជាងរបៀបរៀនផ្សេងៗទៀត? _____%

ចំណុចសំខាន់ដែលត្រូវកត់សម្គាល់ក្នុងតេស្តនេះគឺពិន្ទុត្រូវបានសរុបតាមរបៀបរៀននីមួយៗ ។ ពោលគឺគ្រប់គ្នា ទទួលបានលទ្ធផលពីររបៀបរៀនទាំងបីទៅតាមកម្រិតខុសៗគ្នា ប៉ុន្តែមានរបៀបរៀនមួយដែលលេចធ្លោជាងគេ (ពោលគឺផ្នែកដែលទទួលបានពិន្ទុខ្ពស់ជាងគេ) ។ សូមសួរសិក្ខាកាម ថាតើរបៀបរៀនមួយណាដែលលេចធ្លោជាងគេ ។ ទោះបីជាតេស្តនេះមិនបានវាយតម្លៃរបៀបរៀនផ្សេង

ទៀតដូចជា *ការរៀនចេះចេញពីខ្លួនឯង និងការរៀនចេះពីក្រុម*ក៏ដោយ ក៏លំហាត់នេះបានផ្តល់បទពិសោធន៍សម្រាប់គ្រូយល់ដឹងពីរបៀបរៀនរបស់សិស្ស ។

ក្នុងក្រុមតូច សូមឱ្យសិក្ខាកាមមើលលំហាត់នៅខាងចុងឯកសារ ៣.២.១ ហើយឱ្យពួកគេធ្វើចំណាត់ថ្នាក់របៀបរៀនផ្អែកតាមការពន្យល់ខាងដើម ។ សូមបញ្ជាក់ប្រាប់សិក្ខាកាមថា សិស្សម្នាក់អាចមានរបៀបរៀនលេចធ្លោលើសពីមួយ ។ ផ្តល់ពេលប្រហែល១០នាទីសម្រាប់ធ្វើលំហាត់នេះ បន្ទាប់មកត្រួតពិនិត្យចម្លើយជាក្រុមធំ ។

## ហេតុអ្វីត្រូវបង្កើតប្រវត្តិទិន្នន័យសិស្ស?

ចាប់ផ្តើមការបង្រៀនដោយប្រើប្រាស់សំណួរ៖

*តើគ្រូបង្រៀនអាចចងចាំភាពខុសគ្នារវាងសិស្សទាំងអស់របស់ខ្លួនបានឬទេ? តើមានឧបករណ៍អ្វីដែលអាចប្រើប្រាស់សម្រាប់កត់ត្រាភាពខុសគ្នាទាំងនេះ?*

នៅក្នុងការពិភាក្សា ទំនងជាសិក្ខាកាមនឹងសម្តែងអារម្មណ៍ថាមានបញ្ហាប្រឈមក្នុងការកត់ត្រាសិស្សដែលមានចំនួនច្រើនទាក់ទងនឹង ភាពខ្លាំង របៀបរៀន ចំណាប់អារម្មណ៍ ។ល។ ដោយសារតែសិស្សមានចំនួនច្រើននេះហើយ ទើបមានការស្នើឱ្យគ្រូបង្រៀនបង្កើត **ប្រវត្តិទិន្នន័យសិស្ស** ដើម្បីជួយពួកគេចងចាំ និងកត់ត្រាភាពខុសគ្នា/ភាពប្រែប្រួលក្នុងចំណោមសិស្សទាំងអស់ ។

ផ្តល់ឯកសារចែក ៣.២.២ ដែលបង្ហាញពីឧទាហរណ៍នៃ "ប្រវត្តិទិន្នន័យសិស្ស" ។ ប្រវត្តិទិន្នន័យ ព័ត៌មានត្រូវបំពេញសម្រាប់សិស្សនីមួយៗ ។ សម្រាប់គម្រោងសៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ គ្រូបង្រៀនគ្រាន់តែបំពេញប្រវត្តិទិន្នន័យសម្រាប់សិស្សក្នុងក្រុម ក និង ឃ ប៉ុណ្ណោះ ។

ត្រួតពិនិត្យទម្រង់ប្រវត្តិទិន្នន័យសិស្សរួមគ្នាជាក្រុមធំ និងបញ្ជាក់ឱ្យច្បាស់នូវចំណុចខាងក្រោម៖

<u>ចំណុចដឹកនាំការពិភាក្សា</u>

- ទម្រង់ប្រវត្តិទិន្នន័យសិស្សចែកជាពីរផ្នែក ។ ផ្នែកទី I ផ្តល់ព័ត៌មានមូលដ្ឋាន

ទាក់ទងនឹងជីវប្រវត្តិសិស្ស របៀបរៀន ។ល។ ព័ត៌មានមួយចំនួនទាំងនេះអាចនឹងមិនមានការផ្លាស់ប្តូរទេ (ឧទា. របៀបរៀន) ។

គំរូប្រវត្តិទិន្នន័យសិស្ស


ទម្រង់ប្រវត្តិទិន្នន័យសិស្ស

*សេចក្តីណែនាំ:* សូមបំពេញព័ត៌មានផ្ទាល់ខ្លួនសម្រាប់សិស្សម្នាក់ៗក្នុងចន្លោះខាងក្រោម:

| | | | |
|---|---|---|---|
| ឈ្មោះសិស្ស: | ______ | សាលារៀន: | ______ |
| ថ្នាក់: | ______ | ភេទ: | □ ប្រុស □ ស្រី |
| អាយុ: | ______ | ស្ថានភាពឡើងថ្នាក់: | □ ត្រួតថ្នាក់ □ ឡើងថ្នាក់ |
| ឈ្មោះគ្រូ: | ______ | បំពេញក្នុងឆមាសទីប៉ុន្មាន? | □ ឆមាសទី១ □ ឆមាសទី២ |

**ផ្នែកទី១: ព័ត៌មានមូលដ្ឋាន**

**ក. ភាពខ្លាំង និងភាពខ្សោយ**

*សេចក្តីណែនាំ:* សូមបំពេញការវាយតម្លៃរបស់អ្នកអំពីភាពខ្លាំង និងខ្សោយរបស់កុមារ និងភាពប្រែប្រួលផ្សេងៗដែលអ្នកបានសង្កេតឃើញក្នុងកំឡុងពេលបង្រៀនប្រចាំខែតាមដំណាក់កាលនីមួយៗ ។

| ផ្នែកបំណិន: | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | | ខែ: ___ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| ការស្គាល់ស្វរបំណិនស្តាប់ | | | | | | | | | | | | | | | | | | |

- ប្រវត្តិទិន្នន័យសិស្សមានព័ត៌មានអំពី ភាពខ្លាំង ភាពខ្សោយ របៀបរៀន និងចំណាប់អារម្មណ៍របស់សិស្ស ។
- គ្រូបង្រៀនគួរកត់ត្រាព័ត៌មានយោងទៅតាមបញ្ជីសិស្សក្នុងថ្នាក់រៀន (ឧទា. ឈ្មោះ ភេទ ត្រួតថ្នាក់ ឡើងថ្នាក់ ។ល។) បណ្ណរបាយការណ៍ពីមុន និងការសង្កេតផ្ទាល់ខ្លួន ។
- ផ្នែកទី II នៃប្រវត្តិទិន្នន័យសិស្សផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពប្រចាំខែអំពីបញ្ហារបស់សិស្ស ភាពរីកចម្រើន និងប្រភេទសកម្មភាពដែលបានជួយដល់ពួកគេ ។
- ព័ត៌មានភាគច្រើនក្នុងប្រវត្តិទិន្នន័យមានទម្រង់ជាបញ្ជីផ្ទៀងផ្ទាត់ ដូច្នោះគ្រូបង្រៀនងាយស្រួលក្នុងការកត់ត្រា និងធ្វើបច្ចុប្បន្នភាព ។
- ព័ត៌មានដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំខែគឺផ្អែកលើស្តង់ដាអំណានដែលគ្រូបានប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃ ។ ការវាយតម្លៃទាំងនេះផ្តល់នូវព័ត៌មានជាក់ស្តែងសម្រាប់គ្រូប្រើប្រាស់សម្រាប់ធ្វើបច្ចុប្បន្នភាពលើផ្នែកទាំងអស់នេះ ។

## របៀបបំពេញទម្រង់ប្រវត្តិទិន្នន័យសិស្ស

បន្ទាប់ពីពន្យល់ទម្រង់ប្រវត្តិទិន្នន័យសិស្ស អ្នកសម្របសម្រួលជួយសិក្ខាកាមឱ្យទទួលបានបទពិសោធន៍ក្នុងការបំពេញទម្រង់នេះតាមរយៈការធ្វើលំហាត់ជាក់ស្តែង ដែលក្នុងនោះពួកគេត្រូវប្តូរព័ត៌មានក្នុងករណីសិក្សារបស់សិស្សប្រឌិតម្នាក់ឈ្មោះ *មិញ វដ្ឋា* ទៅក្នុងទម្រង់ប្រវត្តិទិន្នន័យសិស្ស ។

ដើម្បីបំពេញកិច្ចការនេះ សូមផ្តល់ឯកសារចែក ៣.២.៣ ទៅសិក្ខាកាម ។ ត្រួតពិនិត្យករណីសិក្សានេះរួមគ្នា បន្ទាប់មកសួរសំណួរដើម្បីឱ្យពួកគេអាចបំពេញប្រវត្តិទិន្នន័យសិស្សឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ផ្អែកលើព័ត៌មានដែលបានអានក្នុងករណីសិក្សា ។ ពួកគេគួរបំពេញព័ត៌មានជីវប្រវត្តិទាំងអស់តាំងពីផ្នែកដំបូង ព្រមទាំងព័ត៌មានអំពីរបៀបរៀន ចំណាប់អារម្មណ៍ ភាពខ្លាំង ភាពខ្សោយ និងភាពប្រែប្រួលដែលគេបានរាយការណ៍ ។

សកម្មភាពនេះគួរធ្វើក្នុងក្រុមតូច ។ សូមផ្តល់ពេលប្រហែល១០នាទីសម្រាប់សិក្ខាកាមបំពេញកិច្ចការនេះ ។ នៅពេលសិក្ខាកាមបំពេញទម្រង់ប្រវត្តិទិន្នន័យនេះចប់ ចូរពិភាក្សារួមគ្នាជាក្រុមធំ ។

# មេរៀន ៣.៣ ការរៀបក្រុមសិស្ស និងហានិភ័យដែលត្រូវជៀសវាង

ម៉ោងកំណត់: ៩០ នាទី

ការរៀបចំរបស់គ្រូឧទ្ទេស:

- សរសេរលទ្ធផលសិក្សានៃមេរៀនលើក្រដាសផ្ទាំងដើម្បីចាប់ផ្តើមមេរៀន។
- ថតចម្លងឯកសារចែក ៣.៣.១: *ការបង្រៀនក្រុមដែលមានសមត្ថភាពមធ្យម (កណ្តាល) ក្នុងថ្នាក់រៀន*
- ថតចម្លងឯកសារចែក ៣.៣.២: *ករណីសិក្សា: ការដាក់ស្លាកសិស្ស និងការរំពឹងទុករបស់គ្រូបង្រៀន*
- ថតចម្លងឯកសារចែក ៣.៣.៣: *សេចក្តីសង្ខេបពាក្យ និងបញ្ញត្តិសំខាន់ៗនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព*
- ថតចម្លងឯកសារចែក ៣.៣.៤: *គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្ស*
- ថតចម្លងឯកសារចែក ៣.៣.៥: *គោលការណ៍ណែនាំពីការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព*

ធនធាន/សម្ភារៈ:

- ក្រដាសផ្ទាំង ហ្វឺតបារ
- ក្រដាសផ្ទាំងដែលសង្ខេបពីលទ្ធផលសិក្សានៃមេរៀន
- ឯកសារចែក ៣.៣.១: ការបង្រៀនក្រុមដែលមានសមត្ថភាពកម្រិតមធ្យម (កណ្តាល) ក្នុងថ្នាក់រៀន
- ឯកសារចែក ៣.៣.២: ករណីសិក្សា: ការដាក់ស្លាកសិស្ស និងការរំពឹងទុករបស់គ្រូបង្រៀន
- ឯកសារចែក ៣.៣.៣: សេចក្តីសង្ខេបពាក្យ និងបញ្ញត្តិសំខាន់ៗនៃការ

រៀបក្រុមសិស្សតាមកម្រិតសមត្ថភាព

- ឯកសារចែក ៣.៣.៤: គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្ស
- ឯកសារចែក ៣.៣.៥: គោលការណ៍ណែនាំពីការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព

លទ្ធផលសិក្សា:

- សិក្ខាកាមអាច**ពន្យល់**ពីគ្រោះថ្នាក់នៃការបង្រៀនដែលតម្រូវតាមសិស្សដែលមានសមត្ថភាពកម្រិតមធ្យម (កណ្ដាល)
- សិក្ខាកាមអាច**ពន្យល់**ពីគុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្សទៅតាមសមត្ថភាពចំណេះដឹងរបស់ពួកគេ ។
- សិក្ខាកាមអាច**កំណត់**ពីសេចក្ដីថ្លែងដែល "ត្រូវ" និង "ខុស" ទាក់ទងនឹងគោលការណ៍រៀបចំក្រុមសិស្ស ។
- សិក្ខាកាមអាច**ចាត់ថ្នាក់**បញ្ជីសិស្សប្រឌិតទៅជាក្រុមតាមកម្រិតសមត្ថភាពដោយផ្អែកលើទិន្នន័យសិក្សាដែលបានផ្ដល់ជូន ។

## ជំហាននៃការបំប៉ន

### លទ្ធផលសិក្សា នៃមេរៀន

បិតក្រដាសផ្ទាំងនៅលើក្ដារខៀនដែលសង្ខេបពីលទ្ធផលសិក្សាសម្រាប់មេរៀន ។ សូមពន្យល់លទ្ធផលសិក្សា ហើយបញ្ជាក់ថានេះគួរជាអ្វីមួយដែលសិក្ខាកាមអាចធ្វើបាននៅចុងបញ្ចប់មេរៀន ។

### តើការបង្រៀន "សិស្សដែលមានសមត្ថភាពកម្រិតមធ្យម (កណ្ដាល)" មានន័យដូចម្ដេច ?

ចាប់ផ្ដើមការបង្រៀនដោយចោទសួរសំណួរមួយចំនួនទៅសិក្ខាកាមអំពីកម្រិតសិក្សាខុសៗគ្នានៃសិស្សនៅក្នុងថ្នាក់រៀនគិតជាមធ្យម៖

*តើអ្នកអាចរៀបរាប់ពីសមត្ថភាពសិក្សារបស់សិស្សក្នុងថ្នាក់រៀនគិតជាមធ្យមដោយ*

*របៀបណាដែរ?*

*តើសមត្ថភាពសិក្សារបស់សិស្សភាគច្រើនក្នុងថ្នាក់រៀនទូទៅមានកម្រិតណា?*

*តើជាធម្មតាមានសិស្សដែលរៀនពូកែ និងរៀនយឺតនៅក្នុងថ្នាក់រៀនបែបនោះដែរឬទេ?*

នៅក្នុងការពិភាក្សារបន្ទាប់ អ្នកសម្របសម្រួលគួរព្យាយាមធ្វើឱ្យសិក្ខាកាមយល់ដឹងថាសិស្សភាគច្រើនអាចមានសមត្ថភាពកម្រិតកណ្តាល ខណៈដែលមានសិស្សផ្សេងៗទៀតមានសមត្ថភាពពូកែខ្លាំង និងទាបខ្លាំង ។




ដើម្បីបកស្រាយចំណុចខាងលើ អ្នកសម្របសម្រួលផ្តល់ឯកសារចែក ៣.៣.១ ហើយត្រួតពិនិត្យខ្លឹមសារជាមួយសិក្ខាកាម ។ រូបក្រាហ្វិកដែលបង្ហាញក្នុងឯកសារចែក បកស្រាយអំពីកម្រិតសមត្ថភាពបែកចែកគ្នានៃសិស្សនៅក្នុងថ្នាក់រៀនជាទូទៅ ។ ខ្សែកោងនេះ ត្រូវបានគេហៅជាទូទៅថា "កណ្ដឹង" ពីព្រោះវាមានរូបរាងដូចកណ្ដឹង ។ តាមរយៈដ្យាក្រាមនេះ សិក្ខាកាមអាចមើលឃើញថា សិស្សភាគច្រើនគឺជាធម្មតាស្ថិតនៅចំណុចកណ្តាល ។ ដូច្នោះ គ្រូតែងតែរៀបចំការបង្រៀនរបស់ខ្លួនឆ្លើយតបទៅសិស្សដែលមានចំនួនច្រើនជាងគេ ។ អ្នកអប់រំបានហៅការបង្រៀនបែបនេះថា "ជាការបង្រៀនផ្តោតតែសិស្សមានសមត្ថភាពកម្រិតកណ្តាល" ។

តើនឹងមានអ្វីកើតឡើងចំពោះសិស្សដែលមានសមត្ថភាពកម្រិតខ្ពស់ និងទាបគ្រាដែលគ្រូបង្រៀនផ្តោតតែសិស្សដែលមានសមត្ថភាពកម្រិតកណ្តាល? ដូចដែលបានកត់សម្គាល់ក្នុងឯកសារចែក សិស្សទាំងនេះត្រូវបានគេទុកចោល ។ សួរសិក្ខាកាម តើយើងអាចឆ្លើយតបចំពោះបញ្ហានេះដោយរបៀបណា? តាមរយៈឯកសារចែកដែលបានផ្តល់ជូន គេអាច *រៀបចំជាក្រុមសិស្សដែលមានសមត្ថភាពដូចគ្នា* ក៏បាន ។ ប៉ុន្តែវិធីនេះគឺមានហានិភ័យខ្ពស់ ។

## តើការរៀបចំក្រុមសិស្សតាមកម្រិតសមត្ថភាពអាចមានហានិភ័យអ្វីខ្លះ?

អ្នកសម្របសម្រួលអាចលើកឡើងពីហានិភ័យពីការរៀបចំក្រុមសិស្សតាមសមត្ថ

ភាពដល់សិក្ខាកាមទាំងអស់ ។ ដើម្បីបកស្រាយឱ្យបានងាយស្រួលលើកិច្ចការនេះ អ្នកសម្របសម្រួលគួរប្រើប្រាស់ករណីសិក្សាដែលមានក្នុងឯកសារ ៣.៣.២ ។ សូមផ្តល់ឯកសារចែក និងអានឱ្យសិក្ខាកាមស្តាប់៖

*អ្នកស្រាវជ្រាវមួយក្រុមបានធ្វើពិសោធន៍ដោយឱ្យសិស្សទាំងអស់ក្នុងថ្នាក់ធ្វើតេស្ត ។ ពួកគេបានធ្វើចំណាត់ថ្នាក់ពិន្ទុសិស្សពីខ្ពស់មកទាប ។ បន្ទាប់មកពួកគេបានបញ្ច្រាសសិស្សទាំងនោះដោយសិស្សដែលបានពិន្ទុខ្ពស់ត្រូវទទួលពិន្ទុទាប ហើយសិស្សដែលទទួលបានពិន្ទុទាបត្រូវទទួលបានពិន្ទុខ្ពស់វិញ ។ បន្ទាប់មកពួកគេបានយកបញ្ជីសិស្សនិងពិន្ទុដែលបានបញ្ច្រាសទៅបង្ហាញគ្រូបង្រៀនដែលមកថ្មីដែលត្រូវទៅបង្រៀនសិស្សទាំងនេះ ។ គួរឱ្យភ្ញាក់ផ្អើល អ្នកស្រាវជ្រាវរកឃើញថាសិស្សដែលគ្រូបង្រៀនបានគិតថាជាសិស្សដែលទទួលបានពិន្ទុខ្ពស់ ពិតជាទទួលបានចំណាត់ថ្នាក់ខ្ពស់ ចំណែកឯសិស្សដែលគ្រូបានគិតថាទទួលបានពិន្ទុទាបពិតជាទទួលបានចំណាត់ថ្នាក់ទាប បើទោះបីជាពួកគេធ្លាប់ជាសិស្សពូកែពីមុនក៏ដោយ ។*

បន្ទាប់ពីអានករណីសិក្សាខាងលើចប់ អ្នកសម្របសម្រួលសួរសិក្ខាកាមថា ហេតុអ្វីបានជាសិស្សដែលធ្លាប់ពូកែ បែជាទទួលបានពិន្ទុទាប ហើយសិស្សដែលធ្លាប់រៀនមិនសូវពូកែ បែជាទទួលបានពិន្ទុខ្ពស់? សូមជជែកជាមួយសិក្ខាកាមដោយបង្ហាញពាក្យទាំងឡាយខាងក្រោម៖

*ការមាក់ងាយ (ស្លាកស្នាមទុយ៌ស) ការដាក់ស្លាក ទំនាយដែលកំណត់ដោយបុគ្គលខ្លួនឯង ការរំពឹងទុក*

ក្នុងការពិភាក្សា សូមលើកឡើងនូវចំណុចខាងក្រោមប្រាប់សិក្ខាកាម៖

- តាមរយៈការដាក់ពិន្ទុតេស្តដើម្បីកំណត់ស្លាកសិស្ស សិស្សមួយចំនួនទទួលយល់ថាសមត្ថភាពខ្លួនត្រូវបានមាក់ងាយ ។
- គ្រូបានបង្កើតនូវការរំពឹងទុកមួយអំពីកម្រិតសមត្ថភាពសិស្សថា សិស្សមួយចំនួនពូកែ និងមួយចំនួនទៀតមិនពូកែ ។
- សិស្សបានដឹងពីការរំពឹងទុករបស់គ្រូ ដែលរឹតតែជួយជំរុញឱ្យខ្លួនគេជឿថាខ្លួនគេអាចធ្វើបានល្អ ឬមិនអាចធ្វើបាន ។ សិស្សណាដែលគ្រូផ្តល់ការរំពឹងទុកបែប

វិជ្ជមានរៀនបានពូកែ ហើយសិស្សណាដែលគ្រូមានការរំពឹងទុកអវិជ្ជមានរៀនខ្សោយ ។



ករណីសិក្សាខាងលើ បានបង្ហាញពីគ្រោះថ្នាក់នៃការរៀបក្រុមសិស្សតាមសមត្ថភាពពីព្រោះវាអាចនាំទៅរកទិដ្ឋភាពអវិជ្ជមានដូចជា *ការរំពឹងទុក ការដាក់ស្លាក ការមាក់ងាយ និងទំនាយដែលកំណត់ដោយខ្លួនឯង* ។ សូមផ្តល់ឯកសារចែក ៣.៣.៣ ដែលពន្យល់ពីបញ្ញត្តិទាំងនេះដល់សិក្ខាកាម ។ ចូរត្រួតពិនិត្យខ្លឹមសារទាំងនេះជាក្រុមធំ ។

## គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្សតាមសមត្ថភាព

បន្តការពិភាក្សាជាមួយសិក្ខាកាមដោយបញ្ជាក់ថា បើទោះបីជាមានហានិភ័យអំពីការរៀបចំក្រុមតាមកម្រិតសមត្ថភាព ក៏វាមានគុណសម្បត្តិផងដែរ ។ បើសិនជាយើងអាចគ្រប់គ្រងហានិភ័យបាន យើងនឹងទទួលបានគុណសម្បត្តិ ។

បន្ទាប់មក ផ្តល់ឯកសារចែក ៣.៣.៤ ដល់សិក្ខាកាម ។ ឯកសារនេះសង្ខេបអំពីគុណសម្បត្តិ និងគ្រោះថ្នាក់នៃការរៀបចំក្រុមសិស្សតាមសមត្ថភាព ។ គុណសម្បត្តិសំខាន់ៗដែលត្រូវពន្យល់សិក្ខាកាមរួមមាន៖

- *សិស្សដែលរៀនខ្សោយអាចរៀនទៅតាមដំណើររបស់ខ្លួន*
- *គ្រូបង្រៀនអាចធ្វើការជិតស្និទ្ធជាមួយសិស្សដែលត្រូវការជួយច្រើន*
- *សិស្ស (ដែលមានអំណោយទាន) អាចទទួលបានឱកាសបែបប្រកួតប្រជែងងាយស្រួលជាង*

ទោះបីជាយ៉ាងណា មានគុណវិបត្តិមួយចំនួនដូចជា៖

- *លទ្ធភាពទទួលបានការផាត់ចេញ និងការថប់បារម្ភ*
- *សិស្សដែលស្ថិតនៅក្នុងក្រុមកម្រិតទាប អាចរៀនតាមតែកម្រិតនោះរហូត ។*

កំឡុងពេលពិភាក្សានេះ សូមបញ្ជាក់ជាមួយសិក្ខាកាមថា គ្រូបង្រៀនអាចបង្រួមហានិភ័យនេះឱ្យនៅតូចដោយ៖

- *ការធានាថាសិស្សអាចផ្លាស់ប្តូរក្រុមទៅវិញទៅមករវាងក្រុមដែលដាក់ចម្រុះ និង*

*តាមកម្រិតសមត្ថភាព ។*

- *សិស្សអាចប្តូរក្រុមនៅពេលដែលពួកគេគិតថាពួកគេមានភាពរីកចម្រើនឡើង*
- *ការធានាថាសិស្សមានការរំពឹងទុកបែបវិជ្ជមាន ហើយជំរុញការផ្លាស់ប្តូរបែបស្ថាបនាដោយសិស្សខ្លួនឯង ។*

## គោលការណ៍ណែនាំរៀបចំក្រុមសិស្សដើម្បីបង្រៀនឆ្លើយតបតម្រូវការសិស្ស

ការបង្រៀនចុងក្រោយនេះ គួរតែបង្ហាញសិក្ខាកាមអំពីគោលការណ៍ណែនាំជាក់ស្តែងពីរបៀបរៀបក្រុមក្នុងថ្នាក់រៀន។ ដើម្បីឆ្លើយតបគោលបំណងនេះ អ្នកសម្របសម្រួលចែកគោលការណ៍ណែនាំដែលមានសរសេរក្នុងឯកសារចែក ៣.៣.៥ ។ គោលការណ៍ទាំងនេះត្រូវត្រួតពិនិត្យរួមគ្នាជាក្រុមធំដោយផ្តោតលើចំណុចសំខាន់ៗខាងក្រោម៖

- គ្រូអាចរៀបចំក្រុមចម្រុះសមត្ថភាពដែលធ្លាប់ធ្វើជាធម្មតា ព្រមទាំងការរៀបក្រុមតាមកម្រិតសមត្ថភាពសម្រាប់តែពេលរៀនអំណានដោយផ្អែកលើលទ្ធផលភាពស្ទាត់ជំនាញផ្នែកអំណាន ។
- ក្នុងថ្នាក់អាចមានក្រុមអំណានចំនួន៤ ដែលមួយក្រុមៗអាចមានសិស្សពី៨ទៅ ១០នាក់ ។
- ក្រុម D គឺជាក្រុមដែលរៀនពូកែ ហើយក្រុម A គឺជាក្រុមដែលសិស្សជាច្រើនជួបបញ្ហាក្នុងការអាន ។
- ការកំណត់អំពីក្រុមអំណាន ថាសិស្សណាត្រូវចូលក្រុមមួយណា ត្រូវផ្អែកលើពិន្ទុចុងឆមាសទី១
- ក្រុមអំណានទាំងអស់គួរផ្តល់ពេល៣០នាទីក្នុងមួយថ្ងៃ ដោយធ្វើដំណាលគ្នា ហើយពួកគេធ្វើកិច្ចការដែលគ្រូបានដាក់ជូន ។
- នៅចុងក្រោយនៃរយៈពេល៣០នាទី សិស្សគួរត្រឡប់ទៅកាន់ក្រុមដែលរៀបចម្រុះសមត្ថភាពវិញ ។

បន្ទាប់ពីត្រួតពិនិត្យគោលការណ៍ទាំងនេះ សូមឱ្យសិក្ខាកាមធ្វើការជាក្រុមតូចដើម្បីបំពេញលំហាត់ដែលបានផ្តល់ជូននៅខាងចុងឯកសារចែក ។ សូមផ្តល់ពេល១៥នាទីដើម្បីធ្វើកិច្ចការនេះ ។

បន្ទាប់ពីក្រុមនីមួយៗបានបញ្ចប់លំហាត់នេះ សូមត្រួតពិនិត្យចម្លើយ និងសំណួរ

ដែលសិក្ខាកាមអាចសួរ ជាក្រុមធំ ។

## ផ្នែកទី២: ការគ្រប់គ្រងថ្នាក់រៀន

## មេរៀន ៣.៤ ការរៀបចំថ្នាក់រៀន ការគ្រប់គ្រងពេលវេលា និងការធ្វើផែនការមេរៀន

ម៉ោងកំណត់: ២.៥ ម៉ោង

ការរៀបចំរបស់គ្រូឧទ្ទេស:

- សរសេរលទ្ធផលសិក្សានៃមេរៀនដាក់លើក្រដាសផ្ទាំងដើម្បីចាប់ផ្តើមមេរៀន ។
- ថតចម្លងឯកសារចែក ៣.៤.១: *ការណែនាំអំពីការគ្រប់គ្រងពេលវេលា*
- ថតចម្លងឯកសារចែក ៣.៤.២: *ការស្វែងយល់ពីរបៀបរៀបចំថ្នាក់រៀនដែលជួយជំរុញដល់វិធីសាស្ត្របង្រៀន*
- ថតចម្លងឯកសារចែក ៣.៤.៣: *ការណែនាំអំពីការរៀបចំថ្នាក់រៀន*
- ថតចម្លងឯកសារចែក ៣.៤.៤: *ការរៀបចំប្លង់ថ្នាក់រៀន*
- ថតចម្លងឯកសារចែក ៣.៤.៥: *ប្លង់ផែនការបង្រៀនបន្ថែម*
- ថតចម្លងឯកសារចែក៣.៤.៦: *សកម្មភាព និងសម្ភារៈដាក់ស្តែងសម្រាប់ប្រើប្រាស់ជាមួយរបៀបរៀនផ្សេងៗ*
- រៀបចំបង្កើតប្លង់ថ្នាក់រៀន និងគ្រឿងសង្ហារឹមធ្វើពីស្មោះដើម្បីឱ្យសិក្ខាកាមអាចយកគម្រូតាម

ធនធាន/សម្ភារៈ:

- ក្រដាសផ្ទាំង ហ្វឺតបារ
- ក្រដាសផ្ទាំងដែលសង្ខេបអំពីលទ្ធផលសិក្សានៃមេរៀន
- ឯកសារចែក ៣.៤.១: ការណែនាំអំពីការគ្រប់គ្រងពេលវេលា
- ឯកសារចែក ៣.៤.២: ការស្វែងយល់ពីរបៀបរៀបចំថ្នាក់រៀនដែលជួយជំរុញដល់វិធីសាស្ត្របង្រៀន

- ឯកសារចែក ៣.៤.៣: ការណែនាំអំពីការរៀបចំថ្នាក់រៀន
- ឯកសារចែក ៣.៤.៤: ការរៀបចំប្លង់ថ្នាក់រៀន
- ឯកសារចែក ៣.៤.៥: ប្លង់ផែនការបង្រៀនបន្ថែម
- ឯកសារចែក៣.៤.៦: សកម្មភាព និងសម្ភារៈជាក់ស្តែងសម្រាប់ប្រើប្រាស់ជាមួយរបៀបរៀនផ្សេងៗ

លទ្ធផលសិក្សា:

- សិក្ខាកាមអាច**រៀបរាប់**សកម្មភាពដែលត្រូវរៀបចំឡើងនៅតាមកៀនសិក្សាផ្សេងៗក្នុងកំឡុងពេលអាន៣០នាទី
- សិក្ខាកាមអាច**រៀបរាប់**ចំណុចសំខាន់ៗក្នុងការរៀបចំថ្នាក់រៀនដើម្បីសម្រួលដល់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស រួមមាន កៀនរៀនពាក្យ កៀនបណ្ណាល័យ និងកៀនអំណាន ។
- សិក្ខាកាមអាច**រៀបចំ**គ្រឿងសង្ហារឹម ដោយប្រើប្រាស់បណ្ណ ឬស្មោទៅជាប្លង់ថ្នាក់រៀន ដោយផ្អែកលើគោលការណ៍បង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស
- សិក្ខាកាមអាចបំពេញផែនការមេរៀនដែលបង្ហាញពីការយល់ដឹងលើគោលការណ៍គ្រប់គ្រងពេលវេលា ដំណាលគ្នានឹងការបង្រៀន

## ជំហាននៃការបំប៉ន

លទ្ធផលសិក្សា

បិតក្រដាសផ្ទាំងនៅលើក្តារខៀនដែលសង្ខេបពីលទ្ធផលសិក្សាសម្រាប់មេរៀន ។ សូមពន្យល់លទ្ធផលសិក្សា ហើយបញ្ជាក់ថានេះគួរជាអ្វីមួយដែលសិក្ខាកាមអាចធ្វើបាននៅចុងបញ្ចប់មេរៀន ។

ការស្វែងយល់ពីគំនិតក្នុងការធ្វើសកម្មភាពដំណាលគ្នា

ចាប់ផ្តើមការបង្រៀនដោយការពន្យល់ថា ដើម្បីឱ្យ*ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស*ប្រព្រឹត្តទៅដោយប្រសិទ្ធភាព សិស្សត្រូវធ្វើកិច្ចការពិសេសៗដែលស្រប

ទៅនឹងតម្រូវការរបស់ពួកគេក្នុងការអាន ។ ពោលគឺផ្នែកមួយនៃការរៀនប្រចាំថ្ងៃ សិស្សត្រូវធ្វើសកម្មភាពផ្សេងៗគ្នាក្នុងពេលដំណាលគ្នាទៅតាមក្រុមដែលបានរៀបចំ ។ សូមចង្អុលទៅរូបភាពដែលមាននៅក្នុងឯកសារចែក ។



សិស្ស៥នាក់ សកម្មភាព៥

ផ្តល់ឯកសារ ៣.៤.១ ដើម្បីត្រួតពិនិត្យពីរបៀបដែលសិស្សធ្វើសកម្មភាពដំណាលគ្នា ដោយពិភាក្សាលើចំណុចសំខាន់ៗក្នុងឯកសារចែក ។ ចំណុចពិភាក្សាសំខាន់ៗរួមមានៈ

<u>ចំណុចពិភាក្សាសំខាន់ៗ</u>

- រយៈពេលសិក្សាពិសេសប្រចាំថ្ងៃមាន៣០នាទី
- ៤ទៅ៥ក្រុមសិស្សត្រូវប្តូរវេនគ្នាទៅសិក្សានៅកៀនមួយក្នុងចំណោមកៀនទាំង៤ ជារៀងរាល់ថ្ងៃ ។ សូមមើលដ្យាក្រាមដែលបង្ហាញក្នុងទំព័រទី២នៃឯកសារចែកដែលពន្យល់អំពីដំណើរការក្រុម ។
- គ្រូត្រូវជួបក្រុមមួយក្នុងថ្ងៃនីមួយៗនៅកៀនអំណាន ខណៈដែលសិស្សផ្សេងទៀតធ្វើសកម្មភាពដែលបានគ្រោងទុកដោយម្ចាស់ការខ្លួនឯងនៅតាមក្រុមធម្មតា ឬនៅតាមកៀនសិក្សាពីរផ្សេងទៀតនៅខាងក្រោយថ្នាក់រៀន (ឧទា. កៀនរៀនពាក្យ កៀនបណ្ណាល័យ) ។
- កម្មវិធីដែលកំពុងសាកល្បងនេះ តម្រូវឱ្យបង្កើតកៀនសិក្សាយ៉ាងហោច៣នៅក្នុងថ្នាក់រៀន ។
- គ្រូបង្រៀនត្រូវរៀបចំសកម្មភាពពិសេសជាមុនសម្រាប់កៀនសិក្សានីមួយៗ ដូច្នោះសិស្សនឹងមានគំនិតច្បាស់លាស់ចំពោះកិច្ចការដែលពួកគេត្រូវធ្វើ ។

បន្ទាប់ពីអ្នកសម្របសម្រួលពន្យល់ចប់ ឱ្យសិក្ខាកាមធ្វើការជាក្រុមតូចដើម្បីឆ្លើយសំណួរពិភាក្សាដែលផ្តល់ជូននៅខាងចុងឯកសារចែក ។ សូមផ្តល់ពេលប្រហែល ១០ទៅ១២នាទីសម្រាប់ធ្វើកិច្ចការនេះ ។

នៅពេលសិក្ខាកាមធ្វើសំណួរចប់ សូមត្រួតពិនិត្យចម្លើយជាក្រុមធំ ។

## ការស្វែងយល់ពីទំនាក់ទំនងរវាងការរៀបចំថ្នាក់រៀន និងវិធីសាស្ត្របង្រៀន

អ្នកសម្របសម្រួលចាប់ផ្តើមបង្រៀនដោយជួយសិក្ខាកាមយល់ដឹងពីទំនាក់ទំនងរវាងការរៀបចំថ្នាក់រៀន និងរបៀបដែលយើងចង់បង្រៀន ។ ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ទាមទារការធ្វើសកម្មភាពខុសៗគ្នាក្នុងពេលដំណាលគ្នានៅតាមក្រុមសិស្ស ដូច្នោះវាត្រូវមានការរៀបចំថ្នាក់រៀនជាពិសេស ។ ដើម្បីឱ្យសិក្ខាកាមយល់ដឹងពីទំនាក់ទំនងនេះ សូមផ្តល់ឯកសារចែក ៣.៤.២ ។ សូមអានឯកសារចែករួមគ្នាដោយផ្តោតទៅសំណួរសំខាន់ដែលឱ្យសិក្ខាកាមវិភាគពីទំនាក់ទំនងរវាងរូបភាពទាំងពីរ ។ បន្ទាប់មកឱ្យសិក្ខាកាមពិភាក្សា និងឆ្លើយសំណួរនៅផ្នែកខាងស្តាំនៃឯកសារចែក ។ សូមផ្តល់ពេលប្រហែល១០នាទីសម្រាប់ធ្វើកិច្ចការនេះ ។



*សកម្មភាពក្នុងការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស*

នៅពេលចូលដល់ក្រុមធំ អ្នកសម្របសម្រួលត្រួតពិនិត្យចម្លើយចំពោះសំណួរទាំងអស់ ធ្វើការកត់សម្គាល់ថាការរៀបចំគ្រឿងសង្ហារឹមនៅក្នុងរូបភាពទី១ មិនអាចគាំទ្រសកម្មភាពនៅក្នុងរូបភាពទី២បានឡើយ ពីព្រោះវាចង្អៀតពេកសម្រាប់សិស្សចល័តក្នុងថ្នាក់រៀន ហើយវាក៏មិនមានកៀនសិក្សាពិសេសផងដែរ ។

## សេចក្តីណែនាំពីការរៀបចំថ្នាក់រៀនសម្រាប់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

បន្ទាប់មក ផ្តល់ឯកសារចែក ៣.៤.៣ ឱ្យសិក្ខាកាមទាំងអស់ ។ ឯកសារចែកនេះផ្តល់នូវការណែនាំជាក់ស្តែងអំពីរបៀបបង្កើតថ្នាក់រៀនដែលមានកៀនសិក្សាចំនួន៣សម្រាប់ភាសាខ្មែរ ដែលរួមមាន៖



- កៀនអំណាន
- កៀនរៀនពាក្យ

• កៀនបណ្ណាល័យ

គ្រូតពិនិត្យតួនាទីកៀនសិក្សា និងផ្តល់ឧទាហរណ៍អំពីសម្ភារៈដែលត្រូវដាក់តាមកៀនសិក្សានីមួយៗ និងប្រាប់ពីរបៀបប្រើប្រាស់ ។ សម្ភារៈទាំងនេះរួមមាន លំហាត់៨ចន្លោះ បណ្ណសម្រាប់គូរូប និងអត្ថបទតាមកម្រិតសមត្ថភាព ។

បន្ទាប់ពីការពន្យល់ចប់ ផ្តល់ឱកាសឱ្យសិក្ខាកាមប្រើប្រាស់ប្លង់ស្នើឡើងក្នុងឯកសារចែក ៣.៤.៤ ដើម្បីរៀបជាប្លង់បន្ទប់ជាក់ស្តែងដោយប្រើប្រាស់គម្រូគ្រឿងសង្ហារឹមទាំងបីប្រភេទយោងតាមការណែនាំដែលបានផ្តល់ជូន ។ ផ្តល់សម្ភារៈសម្រាប់រៀបបន្ទប់រៀនដែលមានស្នោសម្រាប់រៀបជាគ្រឿងសង្ហារឹម ។ ផ្តល់សម្ភារៈមួយឈុតសម្រាប់ក្រុមនីមួយៗ ហើយឱ្យពួកគេរៀបចំថ្នាក់រៀនយោងតាមការណែនាំ ។ បន្ទាប់រយៈពេលប្រហែល២០ទៅ២៥នាទី ឱ្យសិក្ខាកាមក្នុងក្រុមនីមួយៗសង្កេតពីថ្នាក់រៀនគម្រូរបស់ពួកគេ ហើយពិភាក្សាពីការកែសម្រួលណាមួយឱ្យកាន់តែមានភាពច្នៃប្រឌិតថែមទៀត ។

គម្រូបន្ទប់រៀន



*ទិដ្ឋភាពមើលទៅផ្នែកខាងមុខបន្ទប់រៀន*



*ទិដ្ឋភាពមើលទៅក្រោយបន្ទប់រៀនដោយមានកៀនអំណាន*

## ការធ្វើផែនការសកម្មភាពក្រុមដោយប្រើប្រាស់កិច្ចតែងការបង្រៀន

ជំហានបន្ទាប់ក្នុងពេលបំប៉នគឺឱ្យសិក្ខាកាមស្គាល់ពីរបៀបប្រើប្រាស់ប្លង់កិច្ចតែងការបង្រៀននៅក្នុង**ឯកសារចែក ៣.៤.៥** ។ សូមផ្តល់ឯកសារចែកនេះទៅសិក្ខាកាមទាំងអស់ រួចពិនិត្យមើលគោលការណ៍ណែនាំនៅទំព័រទី១ ។ ការត្រួតពិនិត្យ

ត្រូវផ្តោតលើ៖

1. *ឧបករណ៍ធ្វើផែនការសកម្មភាពពិសេស* សម្រាប់ក្រុមកម្រិតសមត្ថភាពនីមួយៗអនុវត្តក្នុងថ្នាក់រៀន ។ ដូច្នោះ ត្រូវពិនិត្យមើលប្លង់កិច្ចតែងការនេះឱ្យបានល្អិតល្អន់ ។
2. *ការធ្វើសកម្មភាពក្នុងពេលដំណាលគ្នា* ដែលត្រូវរៀបចំសម្រាប់ក្រុមនីមួយៗ ។
3. *ការកំណត់ពីសកម្មភាព និងសម្ភារៈ* ប្រចាំថ្ងៃ

បន្ទាប់ពីការពន្យល់ចប់ សូមឱ្យសិក្ខាកាមធ្វើលំហាត់ជាក់ស្តែងដែលមានក្នុង ឯកសារចែក ដោយពួកគេត្រូវអានសេចក្តីណែនាំសកម្មភាពក្នុងថ្នាក់រៀន រួចយកព័ត៌មានមកបញ្ចូលក្នុងទម្រង់កិច្ចតែងការបង្រៀន ។ សិក្ខាកាមអាចធ្វើសកម្មភាពនេះជាបុគ្គល ឬក្រុមតូច ។ ផ្តល់ពេលឱ្យសិក្ខាកាមប្រហែល៣០នាទីសម្រាប់សកម្មភាពនេះ ដោយត្រួតពិនិត្យឱ្យបានល្អិតល្អន់ពីសេចក្តីណែនាំ និងខ្លឹមសារជាមួយសិក្ខាកាមជាមុនសិន ។ ជាចុងក្រោយសូមឱ្យសិក្ខាកាមបំពេញទម្រង់កិច្ចតែងការនេះឱ្យបានមួយក្នុងមួយក្រុម ។

នៅពេលសិក្ខាកាមបញ្ចប់កិច្ចការនេះ សូមត្រួតពិនិត្យលទ្ធផលជាក្រុមធំ ដោយប្រៀបធៀបចម្លើយ និងផ្តល់ការពន្យល់បន្ថែមរាល់កំហុសអ្វីមួយដែលបានកើតឡើង ។

# ផ្នែកទី៣: ការវាយតម្លៃថ្នាក់រៀន
# មេរៀន ៣.៥ ការប្រើប្រាស់ស្តង់ដារអំណានសម្រាប់ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស

ម៉ោងកំណត់: ៤ ម៉ោង

ការរៀបចំរបស់គ្រូឧទ្ទេស:

- សរសេរលទ្ធផលសិក្សានៃមេរៀនដាក់លើក្រដាសផ្ទាំងដើម្បីចាប់ផ្តើមមេរៀន
- ថតចម្លងឯកសារចែក ៣.៥.១: *ការស្វែងយល់ពីមូលហេតុដែលយើងធ្វើការវាយតម្លៃ*
- ថតចម្លងឯកសារចែក ៣.៥.២ក: *ការស្វែងយល់ពីបំណិនអានគន្លឹះទាំង៥ដែលជួយជំរុញឱ្យមានភាពស្ទាត់ជំនាញខាងអំណាន*
- ថតចម្លងឯកសារចែក ៣.៥.២ខ: *សេចក្តីសង្ខេបពីបំណិនភាសាខ្មែរទាំងអស់នៅក្នុងសៀវភៅស្តង់ដារអំណាន*
- ថតចម្លងឯកសារចែក ៣.៥.៣: *ការស្វែងយល់ពីទម្រង់សៀវភៅស្តង់ដារអំណាន*
- ថតចម្លងឯកសារចែក ៣.៥.៤: *ការប្រើប្រាស់តេស្តវាយតម្លៃដំណាក់កាលនៅក្នុងសៀវភៅស្តង់ដារអំណាន*
- ថតចម្លងឯកសារចែក ៣.៥.៥: *បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម*
- កំណត់ចំនួនគ្រូបង្រៀនតាមថ្នាក់នីមួយៗដើម្បីបែងចែកសៀវភៅស្តង់ដារអំណាន

ធនធាន/សម្ភារៈ:

- ក្រដាសផ្ទាំង ហ្វឺតបាវ
- ក្រដាសផ្ទាំងដែលសង្ខេបពីលទ្ធផលសិក្សានៃមេរៀន
- ឯកសារចែក ៣.៥.១: ការស្វែងយល់ពីមូលហេតុដែលយើងធ្វើការវាយតម្លៃ
- ឯកសារចែក ៣.៥.២ក: ការស្វែងយល់ពីបំណិនអានគន្លឹះទាំង៥ដែលជួយជំរុញឱ្យមានភាពស្ទាត់ជំនាញខាងអំណាន

- ឯកសារចែក ៣.៥.២ខ: សេចក្តីសង្ខេបពីបំណិនភាសាខ្មែរទាំងអស់នៅក្នុងសៀវភៅស្តង់ដាអំណាន
- ឯកសារចែក ៣.៥.៣: ការស្វែងយល់ពីទម្រង់សៀវភៅស្តង់ដាអំណាន
- ឯកសារចែក ៣.៥.៤: ការប្រើប្រាស់តេស្តវាយតម្លៃដំណាក់កាលនៅក្នុងសៀវភៅស្តង់ដាអំណាន
- ឯកសារចែក ៣.៥.៥: បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម
- សៀវភៅស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣ (សិក្ខាកាមម្នាក់ត្រូវមានសៀវភៅមួយទៅតាមថ្នាក់ដែលដែលពួកគេបង្រៀន)

### លទ្ធផលសិក្សា:

- សិក្ខាកាមអាច**ពន្យល់**ពីរបៀបវាយតម្លៃជាប្រព័ន្ធដែលជួយកែលម្អបំណិនអាន និងសំណេររបស់កុមារ ។
- សិក្ខាកាមអាច**ពន្យល់**ពីបំណិនអានគន្លឹះទាំង៥ដែលជាមូលដ្ឋាននាំទៅរកការអានប្រកបដោយភាពស្ទាត់ជំនាញតាមរយៈការធ្វើលំហាត់ជាក់ស្តែងដែលក្នុងនោះសិក្ខាកាមធ្វើចំណាត់ថ្នាក់កិច្ចការទៅនឹងបំណិនអាន ។
- សិក្ខាកាមអាច**ប្រើប្រាស់**ស្តង់ដាអំណានប្រកបដោយប្រសិទ្ធភាពផ្អែកលើការយល់ដឹងប្រសើរឡើងពីទម្រង់មេរៀននីមួយៗក្នុងសៀវភៅស្តង់ដាអំណាន ។
- សិក្ខាកាមអាច**ប្រើប្រាស់**តេស្តដំណាក់កាលនៅក្នុងសៀវភៅស្តង់ដាអំណានប្រកបដោយប្រសិទ្ធភាពដើម្បី (i) កំណត់រកសិស្សដែលមានតម្រូវការរៀនបន្ថែម (ii) កំណត់រកស្តង់ដាអំណានដែលត្រូវបង្រៀនឡើងវិញ (iii) កំណត់រកសកម្មភាពដែលមានប្រយោជន៍ដែលអាចសម្របសម្រួលការបង្រៀនឡើងវិញ និង (iv) កំណត់រកសម្ភារៈបង្រៀនដែលមានប្រយោជន៍សម្រាប់សម្របសម្រួលការបង្រៀនឡើងវិញ ។

## ជំហាននៃការបំប៉ន

### លទ្ធផលសិក្សា

បិតក្រដាសផ្ទាំងនៅលើក្តារខៀនដែលសង្ខេបពីលទ្ធផលសិក្សាសម្រាប់មេរៀន ។ សូមពន្យល់លទ្ធផលសិក្សា ហើយបញ្ជាក់ថានេះគួរជាអ្វីមួយដែលសិក្ខាកាមអាច

ធ្វើបាននៅចុងបញ្ចប់មេរៀន ។

## ការស្វែងយល់ពីរបៀបវាយតម្លៃដើម្បីពង្រឹងបំណិនអំណាន

ចាប់ផ្តើមការបង្រៀនដោយសួរសិក្ខាកាមថាតើពួកគេធ្លាប់ឮពីស្តង់ដាអំណាន ដែលបានបង្កើតឡើងនាពេលថ្មីៗនេះដោយក្រសួងអប់រំ យុវជន និងកីឡា ។ បង្ហាញសៀវភៅស្តង់ដាអំណានទៅកាន់សិក្ខាកាមទាំងអស់ ។ ចូរធ្វើបញ្ជីអំពីអ្វី ដែលពួកគេបានដឹងអំពីសៀវភៅស្តង់ដាអំណាន ។ តាមរយៈសកម្មភាពនេះ អ្នកសម្របសម្រួលនឹងដឹងពីកម្រិតចំណេះដឹងរបស់សិក្ខាកាមអំពីសៀវភៅស្តង់ដា អំណាន ។ បញ្ជីនេះមានសារៈប្រយោជន៍សម្រាប់កែតម្រូវការយល់ខុសមួយចំនួនអំពីសៀវភៅស្តង់ដាអំណាន ស្របពេលនឹងការបង្រៀនអំពីសៀវភៅនេះ។

បន្ទាប់មក សួរសិក្ខាកាមថា តើទិន្នន័យពីការវាយតម្លៃត្រូវប្រើសម្រាប់ធ្វើអ្វីខ្លះ? អ្នកសម្របសម្រួលត្រូវបង្កើតបញ្ជីចម្លើយនៅលើក្តារខៀនដូចមុន ។ បញ្ជីទាំងនោះអាចមានបញ្ចូលចំណុចខាងក្រោម៖

- ដាក់ក្នុងសៀវភៅពិន្ទុតាមកម្រិតថ្នាក់
- ដើម្បីសម្រេចចិត្តថាសិស្សណាត្រូវជាប់ និងធ្លាក់
- ដើម្បីយកមកបំពេញបណ្ណពិន្ទុសិស្សប្រចាំខែ

អ្នកសម្របសម្រួលនិយាយថា ហេតុផលទាំងអស់នេះគឺត្រឹមត្រូវ ។ ប៉ុន្តែអ្នកសម្របសម្រួលបន្តសួរ តើគ្រូបង្រៀនធ្លាប់ធ្វើតេស្តសិស្សដើម្បីកំណត់អំពីអ្វីដែលត្រូវបង្រៀនឡើងវិញ ឬដើម្បីរកឱ្យឃើញសិស្សដែលមានតម្រូវការរៀនបន្ថែមដែរឬទេ? ចំណុចនេះប្រហែលជាគ្រូបង្រៀនមិន ដែលបានអនុវត្តជាទូទៅឡើយ ប៉ុន្តែគ្រូមួយចំនួនអាចធ្លាប់បានអនុវត្ត ។ ការវាយតម្លៃប្រភេទគេហៅថា ការវាយតម្លៃដើម្បីពង្រឹងចំណេះដឹង (FORMATIVE ASSESSMENT)



ហើយវាជួយពួកយើងក្នុងការកែលម្អការបង្រៀនរបស់យើងឬជួយសិស្សម្នាក់ៗ ។ ការវាយម្លៃបែបនេះគឺវាស្រដៀងគ្នាទៅនឹងអ្វីដែលវេជ្ជបណ្ឌិតបានធ្វើ គឺការធ្វើរោគវិនិច្ឆ័យមុននឹងការផ្ដល់ថ្នាំព្យាបាល ។ ក្នុងករណីនេះ ថ្នាំគឺការស្វែងរកសកម្មភាព និងសម្ភារៈពិសេសមកជួយសិស្សទាំងអស់ឱ្យទទួលបានភាពស្ទាត់ជំនាញផ្នែកអំណាន។

អ្នកសម្របសម្រួលគួរពន្យល់បន្ថែមថា គ្រូភាគច្រើនក្នុងប្រទេសកម្ពុជាមិនបានយល់ដឹងពីភាពខុសគ្នារវាងការវាយតម្លៃផ្សេងៗឡើយ ។ ការវាយតម្លៃសិស្សដែលគេបានធ្វើជាធម្មតាសម្រាប់ការសម្រេចចិត្តឱ្យសិស្សឡើងឬត្រួតថ្នាក់គេហៅថា ការវាយតម្លៃបែបបូកសរុប (SUMMATIVE ASSESSMENT) ។ ការវាយតម្លៃប្រភេទនេះគឺធ្វើនៅចុងបញ្ចប់កម្មវិធីអ្វីមួយ ហើយវាមិនបានជួយសម្រេចចិត្តដើម្បីបង្រៀនឡើងវិញ ឬបំប៉នសិស្សបន្ថែមលើផ្នែកណាមួយឡើយ ។ ការវាយតម្លៃទាំងពីរប្រភេទនេះគឺមានសារៈសំខាន់ដូចគ្នាប៉ុន្តែវាពឹងផ្អែកទៅលើការសម្រេចចិត្តរបស់យើងថាតើត្រូវប្រើប្រាស់ការវាយតម្លៃមួយណា ។ នៅពេលយើងធ្វើការវាយតម្លៃ យើងត្រូវយល់ដឹងពី**មូលហេតុ** ពីព្រោះគោលបំណងរបស់យើងនឹងកំណត់អំពីប្រភេទនៃការវាយតម្លៃដែលយើងត្រូវធ្វើ ។ ពោលគឺយើងត្រូវដឹងពីប្រភេទនៃការសម្រេចចិត្តដែលយើងត្រូវធ្វើដើម្បីកំណត់អំពីប្រភេទនៃការវាយតម្លៃដែលយើងត្រូវធ្វើ ។ សូមសរសេររូបមន្តខាងក្រោមនៅលើក្ដារខៀនដើម្បីសង្ខេបពីបញ្ញត្តិនេះ៖

**ការវាយតម្លៃ ➔ បង្កើតជាព័ត៌មាន ➔ សម្រាប់ធ្វើការសម្រេចចិត្ត**

| *ការបង្រៀនសិស្សមានសមត្ថភាពមធ្យម (កណ្តាល)*   | ការអនុវត្តការបង្រៀនដែលឆ្លើយតបនឹងតម្រូវការតែក្រុមសិស្សភាគច្រើននៅក្នុងថ្នាក់រៀន ដោយផាត់ចោលក្រុមសិស្សដែលមានសមត្ថភាពទាប និងខ្ពស់ ។ |
| *ការមាក់ងាយ*  | សញ្ញាមួយនៃភាពអាម៉ាស់ ឬភាពខ្មាសអៀនដែលកើតចេញពីលក្ខណៈពិសេសណាមួយប្រព្រឹត្តទៅលើសិស្សជាពិសេសដោយសារពួកគេទទួលសមិទ្ធផលការសិក្សាទាប ។ |
| *ការដាក់ស្លាកសិស្ស*  | ការអនុវត្តដែលចាត់សិស្សចូលទៅក្នុងប្រភេទឬក្រុមជាក់លាក់ណាមួយដោយមានលក្ខណៈ "រឹតត្បិត" ឬ "មិនត្រឹមត្រូវ" ឬ សំដៅលក្ខណៈទាំងពីរនេះរួមគ្នា ។ |
| *ទំនាយដោយខ្លួនឯង*  | **ទំនាយដោយខ្លួនឯង**គឺជាការទស្សន៍ទាយមួយដោយផ្ទាល់ឬដោយប្រយោលថាខ្លួនឯងនឹងក្លាយជាការពិតដោយសារតែការឆ្លើយជាវិជ្ជមានរវាងជំនឿនិងអាកប្បកិរិយាមួយ។ |
| *ការរំពឹងទុករបស់គ្រូបង្រៀន*  | ជំនឿរបស់គ្រូបង្រៀនអំពីអាកប្បកិរិយារបស់សិស្សដែលជំនឿនោះនឹងរួមចំណែកដល់ការសម្រេចបាននៃអាកប្បកិរិយានោះ។ ការរំពឹងទុកអាចមានលក្ខណៈអវិជ្ជមានឬវិជ្ជមាន។ |

# ឯកសារចែក ៣.៣.៤: គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព[3]



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| 1. **សិស្សអាចរៀនទៅតាមដំណើរឬល្បឿនរបស់ខ្លួន:** សម្ពាធទៅលើសិស្សក្នុងពេលបង្រៀនប្រធានបទអ្វីមួយត្រូវបានបន្ថយឱ្យនៅតិចនៅពេលដែលសិស្សត្រូវបានដាក់ជាក្រុមរួមគ្នាតាមកម្រិតបំណិនឬសមត្ថភាព ។ សិស្សដែលយល់ពីបញ្ញត្តិអាចបន្តល្បឿនរបស់ខ្លួនទៅមុខទៀតនៅពេលដែលពួកគេបានឈានដល់ការយល់ដឹងសមស្របមួយ។ ដូចគ្នានេះដែរសិស្សដែលមានរបៀបរៀនដែលត្រូវការពេលវេលាយូរដើម្បីយល់ពីគោលគំនិតអ្វីមួយក៏មិនត្រូវបានផាត់ចោលដោយគ្រាន់តែសំអាងថាសិស្សក្នុងថ្នាក់ទាំងមូលត្រូវបន្តសិក្សាទៅមុខទៀត ។ ពួកគេគ្រាន់តែត្រូវការពេលវេលាទៅតាមតម្រូវការនិងបន្តវឌ្ឍនភាពរបស់ខ្លួនតាមពេលវេលាសមស្រប ។ | 1. **លទ្ធភាពនៃការមិនរាប់បញ្ចូលនិងការថប់បារម្ភ:** លទ្ធភាពដែលអាចកើតឡើងគឺថាសិស្សមួយចំនួននឹងជួបប្រទះភាពមិនស្រួលក្នុងអារម្មណ៍នៅពេលដាក់ចូលទៅក្នុងក្រុមមួយដែលត្រូវបានចាត់ទុកថាជាក្រុមកម្រិតទាបជាងឬខ្ពស់ជាងគេ ។ ការរៀបក្រុមក៏បង្ហាញឱ្យឃើញអំពីភាពខុសគ្នានៃសមត្ថភាពចំណេះដឹងក្នុងចំណោមសិស្សនិងអាចនាំឱ្យមានអារម្មណ៍ឯកោនិងការបំបែកពីក្រុមធំ ។ |

[3] Adapted from: https://uoitonlinetech.wordpress.com/2012/06/11/pros-and-cons-of-grouping-students-by-ability/

2. **គ្រូបង្រៀនអាចធ្វើការជិតស្និទ្ធជាមួយសិស្សដែលត្រូវការជំនួយច្រើន:** នៅពេលសិស្សត្រូវបានរៀបជាក្រុមតាមកម្រិតសមត្ថភាព នោះតម្រូវឱ្យមានការងារសហការគ្នាពីព្រោះបរិយាកាសសិក្សាបែបនេះគឺពឹងផ្អែកយ៉ាងខ្លាំងលើការងារជាក្រុម។ ខណៈពេលដែលសិស្សធ្វើការក្រុមរួមគ្នានិងរៀនសូត្រពីគ្នា គ្រូបង្រៀនអាចប្រើពេលវេលាជាមួយសិស្សផ្សេងទៀតដែលត្រូវការយកចិត្តទុកដាក់ជួយមួយទល់មួយ។

3. **សិស្សអាចទទួលបានឱកាសបែបប្រកួតប្រជែងជាង:** សិស្សដែលរៀនរីកចម្រើនបានលឿនតាមរយៈសម្ភារៈកម្មវិធីសិក្សា (ឧទា. សិស្សអំណោយទាន) អាចទទួលបានឱកាសបែបប្រកួតប្រជែងសមស្រប នៅពេលពួកគេកំពុងស្ថិតក្នុងក្រុមដែលមានសមត្ថភាពដូចខ្លួន ។ វិធីនេះសិស្សអំណោយទានបន្តការប្រឹងប្រែងពេញមួយឆ្នាំសិក្សាដោយមិនមានការបាត់បង់សន្ទុះ ខណៈពេលដែលសិស្សផ្សេងទៀតនៅតែកំពុងប្រឹងប្រែងរៀនឱ្យទាន់ ។

2. **សិស្សដែលស្ថិតក្នុងក្រុមកម្រិតសមត្ថភាពទាបជាងគេអាចនឹងរៀនតាមតែកម្រិតនោះរហូត:** បើសិនគេរៀបសិស្សទៅក្នុងក្រុមមួយដែលការសិក្សាមានល្បឿនយឺតជាង ហើយបញ្ញត្តិដែលត្រូវសិក្សាត្រូវចំណាយពេលយូ នោះធ្វើឱ្យសិស្សខ្លះអាចធ្វើការតាមតែកម្រិតក្រុមនោះ ទោះបីជាពួកគេមានសមត្ថភាពច្រើនជាងក៏ដោយ ។ ការរៀបចំបែបនេះបង្កើតជាលទ្ធភាពមួយនៃការចាត់សិស្សទៅតាមកម្រិតប្រភេទនៃភាព "ឆ្លាត" ហើយសិស្សខ្លះនឹងធ្វើការទៅតាមកម្រិតក្រុមដែលខ្លួនស្ថិតនៅ ។ ពេលខ្លះ ទំនោរបែបនេះគេហៅថាជាទំនាយដែលកំណត់ដោយខ្លួនឯង។

## ឯកសារចែក ៣.៣.៥: គោលការណ៍ណែនាំពីការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព

*គោលការណ៍ណែនាំខាងក្រោម បានបង្កើតឡើងដើម្បីជួយគ្រូឱ្យស្វែងយល់របៀបរៀបក្រុមសិស្សនៅពេលបង្រៀនអំណាន និងក្នុងពេលដែលពួកគេមិនបង្រៀនអំណាន ។*

1. **ការរៀបចំក្រុមសិស្សតាមទម្លាប់ថ្នាក់រៀនធម្មតា**
    - សិស្សត្រូវរៀបជាក្រុមតាមទម្លាប់ធម្មតាដែលមានសិស្សចម្រុះសមត្ថភាពគ្នា ។
2. **ការកំណត់ប្រភេទសិស្សដើម្បីដាក់ទៅតាមក្រុមអំណាន**
    - សម្រាប់សកម្មភាពអានពិសេស ត្រូវរៀបសិស្សដែលមានកម្រិតសមត្ថភាពអំណានដូចគ្នាជាមួយគ្នា ។
    - កំណត់រកសិស្សដែលមានកម្រិតសមត្ថភាពដូចគ្នាដោយប្រើប្រាស់លទ្ធផលពិន្ទុឆមាសទី១ ដោយយកតែពិន្ទុផ្នែកភាសាខ្មែរមកកំណត់ប៉ុណ្ណោះ[4]
    - ការចាត់កម្រិតសមត្ថភាពសិស្សទៅតាមក្រុមត្រូវផ្អែកតាមមធ្យមភាគពិន្ទុឆមាសផ្នែកភាសាខ្មែរដូចខាងក្រោម៖
        - មធ្យមភាគពិន្ទុពី ៨.0 ទៅ ១០ គឺស្ថិតក្នុងកម្រិតខ្ពស់ (កម្រិត ឃ)
        - មធ្យមភាគពិន្ទុពី ៥.0 ទៅ ៧.៩ គឺស្ថិតក្នុងកម្រិតមធ្យម (កម្រិត គ)
        - មធ្យមភាគពិន្ទុពី ៣.0 ទៅ ៤.៩ គឺស្ថិតក្នុងកម្រិតលំបាក (កម្រិត ខ)
        - មធ្យមភាគពិន្ទុ 0.0 ទៅ ២.៩ គឺស្ថិតក្នុងកម្រិតលំបាកខ្លាំង (កម្រិត ឃ)
    - ការរៀបចំតម្រូវការទៅតាមក្រុម ត្រូវកត់ត្រាទុកក្នុងប្រវត្តិទិន្នន័យសិស្ស ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺគ្រូត្រូវយល់ដឹងឱ្យច្បាស់អំពីការដាក់ស្លាកសិស្ស ។

3. **ការចាត់ចែងក្រុម**

---

[4]នៅពេលអង្គការខេបប្រើប្រាស់ឯកសារនេះនៅក្នុងគម្រោងផ្សេងៗទៀតដែលចាប់ផ្តើមនៅដើមឆ្នាំសិក្សា យើងនឹងប្រើប្រាស់វិធីសាស្ត្រផ្សេងទៀតដើម្បីកំណត់អំពីកម្រិតសមត្ថភាពសិស្ស ។ ផ្អែកតាមការស្រាវជ្រាវរបស់អង្គការ STS គេអាចកំណត់យកបំណិនអានផ្ទាល់មាត់សម្រាប់ធ្វើជាការវាស់វែងសមត្ថភាពអំណានរួមរបស់កុមារបាន ។

- ដូចការលើកឡើងខាងលើ សិស្សត្រូវរៀបជាក្រុមដោយចម្រុះសមត្ថភាពតាមទម្លាប់ការចាត់ចែងធម្មតានៅក្នុងថ្នាក់រៀន ។ បន្ថែមពីលើនេះ សិស្សអាចត្រូវរៀបចំជាក្រុមអំណានពិសេស ផ្អែកតាមកម្រិតសមត្ថភាពអំណានរបស់ពួកគេ ។ នៅពេលដល់ពេលធ្វើការក្នុងក្រុមពិសេសដែលមានរយៈពេល៣០នាទី គ្រូហៅសិស្សចេញពីក្រុមធម្មតាទៅកាន់ទីតាំងក្រុមដែលរៀបចំជាពិសេសនៅក្នុងថ្នាក់រៀន ។
- ចំនួនសិស្សក្នុងក្រុមតាមកម្រិតសមត្ថភាពអាចកំណត់ពី៨ទៅ១០នាក់ ឬតិចជាងនេះ ។
- ការរៀបចំនួនសិស្សតាមក្រុមគឺផ្អែកលើទំហំថ្នាក់ជាមធ្យមដែលមាន៤០នាក់ឬតិចជាងនេះ ។
- គ្រូបង្រៀននឹងបង្កើតសកម្មភាពអំណានពិសេសសម្រាប់សិស្សតាមក្រុមអំណានទាំងបួន ។ សិស្សនឹងត្រឡប់ទៅកាន់ក្រុមចម្រុះសមត្ថភាពដែលរៀបតាមទម្លាប់ធម្មតាវិញ បន្ទាប់ពីធ្វើការចប់ក្នុងក្រុមតាមកម្រិតសមត្ថភាព (រយៈពេល៣០នាទីក្នុងមួយថ្ងៃ) ។
- គ្រូគួរឱ្យសិស្សកំណត់ឈ្មោះក្រុមដោយខ្លួនឯងដែលអាចជាឈ្មោះសត្វ ពណ៌ ផ្កា ផ្លែឈើ ។ល។ គ្រូបង្រៀនមិនគួរបង្ហាញពីកម្រិតក្រុមនីមួយៗថាជា "ក្រុមសិស្សរៀនយឺត" "ក្រុមសិស្សពូកែ" ។ល។ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

4. **ការផ្លាស់ប្តូររវាងក្រុមមួយទៅមួយ:**

- សិស្សត្រូវគេរំពឹងថានឹងមានការវិវឌ្ឍផ្នែកសមត្ថភាពអំណាន ដូច្នោះវាមានន័យថាសិស្សអាចប្តូរពីក្រុមមួយទៅមួយបានផងដែរ ។
- នៅចុងខែនីមួយៗ គ្រូបង្រៀនគួរពិនិត្យសិស្សក្នុងក្រុមទាំងអស់ និងធ្វើការកំណត់ជាថ្មីថាតើសិស្សអាចប្តូរពីក្រុមមួយទៅមួយទៀតបាន ។ ការកំណត់នេះ អាចផ្អែកលើលទ្ធផលនៃតេស្តដំណាក់កាល កិច្ចការធ្វើនៅផ្ទះ និងការសង្កេតក្នុងថ្នាក់រៀនទូទៅ ។

# លំហាត់: ការរៀបសិស្សជាក្រុម

*សេចក្តីណែនាំ: សូមត្រួតពិនិត្យពិន្ទុភាសាខ្មែរក្នុងឆមាសទី១ រួចរៀបទៅជាកម្រិតក្រុម ។*

| *សិស្ស* | *ពិន្ទុ* | *កម្រិតក្រុម* |
|---|---|---|
| 1. *តារា* | *9.2* | _____ |
| 2. *ប៊ុន* | *5.0* | _____ |
| 3. *ធី* | *1.8* | _____ |
| 4. *ណារី* | *4.5* | _____ |
| 5. *មុនី* | *3.0* | _____ |
| 6. *វណ្ណា* | *4.9* | _____ |
| 7. *សុវណ្ណ* | *7.7* | _____ |
| 8. *វ៉ាន់ថា* | *2.5* | _____ |

*សេចក្តីណែនាំ: សូមត្រួតពិនិត្យសេចក្តីថ្លែងខាងក្រោម រួចកំណត់ថាតើ ត្រូវ ឬ ខុស ។*

| ***សេចក្តីថ្លែង*** | ***ត្រូវ ឬ ខុស*** |
|---|---|
| 1. ក្នុងពេលបង្រៀនទៅកាន់ថ្នាក់ទាំងមូល គ្រូបង្រៀនជាធម្មតាបង្រៀនសិស្សដែលមានសមត្ថភាពកម្រិតមធ្យម (កណ្តាល) ហើយទុកចោលសិស្សដែលមានសមត្ថភាពខ្ពស់ជាង ឬ ទាបជាង ។ | __________ |
| 2. វិធីបង្រៀនដែលល្អបំផុតគឺរៀបសិស្សជាក្រុមជាអចិន្ត្រៃយ៍ទៅតាមកម្រិតសមត្ថភាព ។ | __________ |
| 3. នៅពេលយើងរៀបសិស្សទៅក្នុងក្រុមដែលមានកម្រិតសមត្ថភាពទាបជាងគេ សិស្សទាំងនោះបានដឹងនិងទទួលយកការរៀបចំបែបនេះ ដូច្នោះវាមិនមានបញ្ហាអ្វីឡើយដែលយើងនិយាយជាមួយពួកគេដោយបើកចំហរ ។ | __________ |

| | |
|---|---|
| 4. វាមិនមានបញ្ហាអ្វីទេដែលយើងនិយាយដោយចំហរថា "សិស្សរៀនខ្សោយ" "សិស្សរៀនយឺត" ឬ "សិស្សរៀនមិនទាន់គេ" ។ | ___________ |
| 5. ទោះបីជាមានហានិភ័យទាក់ទងនឹងការរៀបសិស្សជាក្រុមតាមកម្រិតសមត្ថភាពក៏ដោយ វាក៏មានគុណសម្បត្តិច្រើនផងដែរ បើសិនជាយើងចេះគ្រប់គ្រងហានិភ័យទាំងនោះឱ្យបានត្រឹមត្រូវ ។ | ___________ |
| 6. ហានិភ័យមួយក្នុងចំណោមហានិភ័យផ្សេងទៀតទាក់ទងនឹងការរៀបសិស្សជាក្រុមតាមកម្រិតសមត្ថភាពនោះគឺវាអាចនាំទៅរក *ទំនាយដែលកំណត់ដោយខ្លួនឯង* ។ | ___________ |

## ឯកសារចែក ៣.៤.១: គោលការណ៍ណែនាំការគ្រប់គ្រងពេលវេលា

*គោលការណ៍ណែនាំបង្កើតឡើងខាងក្រោមនេះគឺដើម្បីជួយគ្រូបង្រៀនស្វែងយល់ពីរបៀបរៀបចំកាលវិភាគតាមថ្នាក់រៀនទៅតាមសកម្មភាពពិសេសៗដើម្បីពង្រឹងសមត្ថភាពអានដល់សិស្ស។*

1. **ចំនួនម៉ោង:** គ្រូបង្រៀននឹងជួបជាមួយក្រុមពិសេសៗយ៉ាងហោចណាស់២០ ទៅ៣០ នាទីរាល់ថ្ងៃ ដើម្បីរៀបចំសកម្មភាពបន្ថែមដែលស្របតាមប្រវត្តិទិន្នន័យរបស់ពួកគេ។ *ក្រុម ក (ក្រុមដែលមានបញ្ហាប្រឈមបំផុត) នឹងទទួលបានកិច្ចការពីរក្នុងមួយសប្តាហ៍ដែលត្រូវជួបជាមួយគ្រូនៅកៀនអំណាន។*

| ថ្ងៃ | រយៈពេល |
|---|---|
| ចន្ទ | 30 នាទី |
| អង្គារ | 30 នាទី |
| ពុធ | 30 នាទី |
| ព្រហស្បតិ៍ | -- |
| សុក្រ | 30 នាទី |
| សៅរ៍ | 30 នាទី |

2. **កាលវិភាគប្រចាំថ្ងៃសម្រាប់ចល័តសិស្សនៅកៀនសិក្សា:** កិច្ចការដែលសំខាន់គឺគ្រូបង្រៀនត្រូវរៀបចំសកម្មភាពសមស្របសម្រាប់ក្រុមសិស្សសិក្សានៅតាមកៀននីមួយៗ ហើយក្រុមនីមួយៗនឹងមានវេនវិលជុំធ្វើកិច្ចការអំណានពិសេសនេះដោយប្រើរយៈពេល៣០នាទី ជារៀងរាល់ថ្ងៃ ។ កាលវិភាគនេះរួមបញ្ចូលការផ្តល់សៀវភៅពិសេសដើម្បីពង្រឹងកម្រិតនៃការអានដល់កុមារ (ឧ.នៅកៀនអំណាន) ការប្រើប្រាស់ក្រដាសលំហាត់៨ប្រឡោះ ។ល។

3. **ផែនការកាលវិភាគគំរូសម្រាប់មុខវិជ្ជាភាសាខ្មែរ**

| កាលវិភាគ | | | | | |
|---|---|---|---|---|---|
| **រយៈពេល** | ថ្ងៃចន្ទ | ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃសុក្រ | ថ្ងៃសៅរ៍ |
| **30 នាទី** | អនុវត្តតាមកិច្ចតែងការបង្រៀនគ្រូនិងកម្មវិធីសិក្សា | | | | |
| **10 នាទី** | ការផ្តល់សេវាកម្មតាមក្រុម | | | | |
| | ស្វ័យសិក្សា | ស្វ័យសិក្សាដោយប្រើ | កៀនសិក្សា | កៀនបណ្ណាល័យ | កៀនអំណាន |

| | | |
|---|---|---|
| ដោយប្រើប្រាស់ល្បែងសិក្សា (ឧ. TTS) | ប្រាស់ថាប់ប្លែត | ពាក្យ |

**ជម្រើស:**

- ផ្តល់សេវាកម្មដោយផ្អែកលើប្រវត្តិទិន្នន័យសិស្សដល់ក្រុមនីមួយៗ ។ សេវាកម្មទាំងនេះនឹងមានបង្ហាញលម្អិតនៅក្នុងឯកសារបំប៉ន។
- ផ្តល់សេវាកម្មស្មើភាពគ្នាដល់គ្រប់ក្រុមហើយដាក់វេនវិលជុំ ។

4. **ការផ្លាស់ប្តូរសកម្មភាព:** កាលវិភាគក្រុមដែលត្រូវវិលជុំនូវរាល់សកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃមានដូចខាងក្រោមនេះ:

## ការផ្លាស់ប្តូរសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃ

**ថ្ងៃចន្ទ**




**ថ្ងៃអង្គារ**




**ថ្ងៃពុធ**




**ថ្ងៃសុក្រ**



## ថ្ងៃសៅរ៍




*សម្គាល់:*

- ក្រុមត្រូវប្តូរតាមទីតាំងសកម្មភាពផ្សេងៗគ្នា ដើម្បីធ្វើកិច្ចការដែលរៀបចំជាស្រេចទៅតាមតម្រូវការរបស់សិស្ស (ផ្អែកលើប្រវត្តិទិន្នន័យសិស្ស) ចំណាប់អារម្មណ៍ និងរបៀបរៀន (ទៅតាមកម្រិតមួយដែលអាចធ្វើបាន) ។
- ចំពោះក្រុមដែលត្រូវការជួយច្រើន គឺក្រុម ក ក្រុមនេះនឹងជួបគ្នានៅកៀនអំណានពីរដងក្នុងមួយសប្តាហ៍ (ចន្ទ និង សៅរ៍)។
- ថ្ងៃព្រហស្បត៍គឺជាថ្ងៃពិសេសក្នុងប្រទេសកម្ពុជាដែលសិស្សត្រូវធ្វើសកម្មភាពពិសេសៗ នៅខាងក្រៅថ្នាក់រៀន។

## សំណួរពិភាក្សា

1. ដោយយោងទៅតាមដ្យាក្រាមខាងលើសកម្មភាពក្រុមកើតឡើងរាល់ថ្ងៃប៉ុន្តែលើកលែងមួយថ្ងៃ តើថ្ងៃអ្វី?
2. តើសកម្មភាពទាំងបួនដែលឆ្លុះបញ្ចាំងនៅក្នុងដ្យាក្រាមមានអ្វីខ្លះ?
3. តើក្រុម ក ត្រូវចូលរៀននៅកៀនអំណានប៉ុន្មានដង? ហើយចំណែកក្រុម ខ វិញប៉ុន្មានដងដែរ? តើអ្នកមានការយល់ឃើញផ្សេងពីនេះទេ ហើយហេតុអ្វីបានជាអ្នកគិតដូចនេះ?
4. ប្រសិនបើគ្រូនៅជាមួយក្រុម ក នៅថ្ងៃចន្ទនៅកៀនអំណាន តើអ្នកណាជាអ្នកគ្រប់គ្រងសិស្សដទៃទៀតនៅក្រុម ខ គ និង ឃ?

# ឯកសារចែក ៣.៤.២: ការស្វែងយល់ពីរបៀបរៀបចំថ្នាក់រៀនអាចដឹកនាំប្រើវិធីសាស្រ្តក្នុងការបង្រៀន

*សេចក្តីណែនាំ: សូមមើលរូបភាពពីរខាងក្រោមនេះ។ រូបភាពទី១ បង្ហាញពីប្លង់ថ្នាក់រៀនមួយ ហើយមួយទៀតបង្ហាញពីសកម្មភាពជាក់លាក់នៅក្នុងបន្ទប់រៀន។ ធ្វើការជាក្រុម ហើយសម្រេចចិត្តថាតើប្លង់ថ្នាក់រៀនដូចដែលបានបង្ហាញនៅក្នុងរូបភាពទី១អាចគាំទ្រឬដាក់ចេញជាសកម្មភាពទៅតាមបំណងរបស់គ្រូក្នុងការរៀបចំសកម្មភាពក្នុងថ្នាក់រៀនដូចបានបង្ហាញនៅក្នុងរូបភាពទី២ឬទេ?*

**រូបភាពទី១**



**តើរូបភាពទី១អាចចេញជាសកម្មភាពដូចដែលអ្នកបានឃើញក្នុងរូបភាពទី២ឬទេ?**

**រូបភាពទី២**




**សូមសរសេរការវិភាគរបស់អ្នកនៅទីនេះ**

1. តើមានសកម្មភាពប៉ុន្មានដែលកើតឡើងក្នុងពេលដំណាលគ្នា ក្នុងរូបភាពទី២ បើតាមការសង្កេតរបស់អ្នក?

______________________

2. តើមានសកម្មភាពអ្វីខ្លះកើតឡើងក្នុងរូបភាពទី២? ______________________

______________________

______________________

3. តាមរយៈរូបភាពទី១តើសិស្សមានភាពងាយស្រួលក្នុងការបម្លាស់ទីនៅក្នុងថ្នាក់រៀនឬទេ? ហេតុអ្វីមានឬមិនមានភាពងាយស្រួល?______________________

______________________

4. នៅក្នុងរូបភាពទី១ តើមានកន្លែងច្រើនសម្រាប់ក្មេងៗធ្វើការងារដោយឯករាជ្យដែរឬទេ?______________________

______________________

______________________

5. តើរូបភាពទី១អាចចេញជាសកម្មភាពដូចដែលអ្នកបានឃើញក្នុងរូបភាពទី២ឬទេ? ហេតុអ្វីអាចឬមិនអាច?

______________________

______________________

______________________

## ឯកសារចែក ៣.៤.៣: គោលការណ៍រៀបចំថ្នាក់រៀន

*គោលការណ៍ខាងក្រោមនេះត្រូវបានបង្កើតឡើងដើម្បីជួយគ្រូបង្រៀនយល់ដឹងពីរបៀបរៀបចំថ្នាក់រៀននៅពេលបង្រៀនអំណាន។*

1. គ្រូនឹងរៀបចំប្លង់កៀនបន្ទប់រៀនសម្រាប់សិស្សដែលគ្រូត្រូវជួបទៅតាមក្រុមកម្រិតសមត្ថភាពនីមួយៗ។
2. គ្រូនឹងរៀបចំ ទៅតាមប្លង់ជាក់លាក់ដែលមានផ្តល់ជូនស្រាប់ ។ ប្លង់បន្ទប់រៀននឹងមានការវាស់វែងជាក់លាក់សម្រាប់កៀនសិក្សាដែលនៅផ្នែកដែលទំនេរនៃបន្ទប់រៀនសម្រាប់ក្រុមខុសៗគ្នា ដើម្បីធ្វើសកម្មភាពដូចគ្នាក្នុងពេលតែមួយ ខណៈពេលដែលគ្រូកំពុងជួបសិស្សក្រុមផ្សេងទៀត ។ កៀនសិក្សានោះរួមមានដូចខាងក្រោមនេះ៖
   - **កៀនអំណាន**: ស្ថិតនៅផ្នែកខាងក្រោយនៃបន្ទប់រៀន ជាកន្លែងដែលគ្រូជួបជាមួយក្រុមកម្រិតសមត្ថភាពដើម្បីធ្វើសកម្មភាពពិសេសៗ រៀនអំណានដោយដោយប្រើថាប់ប្លែត ។ល។ កៀនអំណានមានកន្លែងសម្រាប់សិស្សអង្គុយជាមួយគ្នាបានស្រួល មានក្តារខៀនតូចមួយនៅលើជញ្ជាំងផ្នែកខាងក្រោយ

     

     សម្រាប់ក្មេងរៀនសរសេរពាក្យ និងល្បះ។ មានប្រអប់ពិសេសដាក់សម្ភារៈសិក្សារួមមាន: បណ្ណសិក្សាចល័ត, ខ្មៅដៃពណ៌, ក្រដាសផាត់ពណ៌, សៀវភៅលំហាត់អំណានផាត់ពណ៌ ។ល។ ដើម្បីដំណើរការសកម្មភាពពិសេសៗទៅតាមរបៀបរៀនជាក់លាក់។ កៀនអំណាន ជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើសកម្មភាពពិសេសៗ និងជាកន្លែងគ្រូទទួលខុសត្រូវលើសកម្មភាពទាំងអស់ដែលសិស្សធ្វើ។

- **កៀនបណ្ណាល័យ:** ជាកូនបណ្ណាល័យដែលអាចដាក់សៀវភៅរឿងនិទានទៅតាមកម្រិតពីងាយៗទៅលំបាក។ សម្ភារៈសិក្សារបស់ TTS ក៏ដាក់បញ្ចូលផងដែរ រួមមានល្បែងអំណានពាក្យ សំណាង់ល្បះ ។ល។ គ្រូអាចពិចារណាដាក់សញ្ញាសម្គាល់ពិសេសស (ឧ. ផ្កាយពណ៌ក្រហម, ផ្កាយពណ៌ទឹកប្រាក់, ល...) នៅលើសៀវភៅដើម្បីបញ្ជាក់ពីកម្រិតសៀវភៅដែលស្របទៅកម្រិតសមត្ថភាពសិស្ស ។ ការប្រើសញ្ញាសម្គាល់បែបណាក៏បានដែរ ប៉ុន្តែសំខាន់មិនត្រូវបង្ហាញឱ្យសិស្សដឹងថាសៀវភៅទាំងនោះត្រូវបានរៀបចំទៅតាមកម្រិតសមត្ថភាពសិស្សខុសៗគ្នានោះទេ។



- **កៀនរៀនពាក្យ:** គ្រូបង្រៀននឹងទទួលបានគោលការណ៍ណែនាំអំពីការរៀបចំសកម្មភាពស្វ័យសិក្សាដោយប្រើកិច្ចការដែលបានបង្កើតឡើងមួយ ឬពីរ ដូចគ្នារៀងរាល់សប្តាហ៍ ប៉ុន្តែមានខ្លឹមសារខុសៗគ្នា។ សកម្មភាពសំខាន់ៗពីរនៃកៀននេះរួមមានក្រដាស់លំហាត់៨ប្រឡោះ ដែលសិស្សត្រូវសរសេរពាក្យ ហើយគូររូបភាពដាក់លើក្រដាស់កិច្ចការទំហំ A4 ហើយបែងចែកជា៨ ប្រឡោះ (លំហាត់ពាក្យ៨ប្រឡោះ) និងមានល្បែងសរសេរបំពេញពាក្យនិងរូបភាពដោយប្រើបណ្ណអ៊ុត។ សកម្មភាពទាំងពីរនឹងមានការបញ្ជាក់ច្បាស់លាស់ដែលគ្រូនឹងទទួលបានក្នុងវគ្គបំប៉ន ។



## ឯកសារចែក ៣.៤.៤: គំរូប្លង់បន្ទប់រៀន

ប្លង់បន្ទប់រៀនខាងក្រោមនេះត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្រៀនពិចារណា នៅពេលរៀបចំបន្ទប់បង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ។




សូមចំណាំថាមានកៀនសិក្សាចំនួនបី ដែលដាក់នៅផ្នែកខាងក្រោយនៃថ្នាក់រៀនដើម្បីពង្រឹងសកម្មភាពអំណានក្នុងពេលជំណាលគ្នា។ សិស្សនៅក្រុមទី៤នឹងបន្តអង្គុយក្នុងក្រុមធម្មតាក្នុងកំឡុងពេលធ្វើសកម្មភាពពិសេស ។

គម្រោងនឹងផ្តល់ជំនួយគ្រឿងសង្ហារឹមទៅសាលារៀនបន្ថែមទៀត (សម្រាប់កៀនអំណាន) និងសម្ភារៈដែលបានផលិតរួចជាស្រេច ដើម្បីឱ្យផ្តល់ភាពងាយស្រួលដល់សាលារៀន ហើយឆ្លើយតបនឹងលក្ខខណ្ឌពិសេសដូចដែលបានរៀបរាប់ខាងក្រោម:

### សំណើប្លង់ថ្នាក់រៀន



# ឯកសារចែក ៣.៤.៥: **គំរូកិច្ចតែងការបង្រៀនបន្ថែម**

1. **ការរៀបចំសម្ភារៈពិសេសៗ:** គ្រូបង្រៀននឹងត្រូវបំពេញបន្ថែមកិច្ចតែងការបង្រៀនបន្ថែម ដោយគ្រោងសកម្មភាពពិសេសជារៀងរាល់សប្តាហ៍សម្រាប់សិស្ស៤ ឬ៥ក្រុមដែលបានកំណត់រួចនៅក្នុងថ្នាក់រៀន។
2. **សកម្មភាពតាមក្រុមដែលត្រូវសិក្សាក្នុងពេលដំណាលគ្នា:** ថ្នាក់រៀននីមួយៗនឹងមានបែងចែកជា ៤ឬ៥ក្រុមដោយមានដាក់សម្គាល់ដោយអក្សរ ក ខ គ និង ឃ ដោយ ឃ ជាក្រុមដែលពូកែជាងគេហើយក្រុម ក ជាក្រុមខ្សោយជាងគេ ។ ក្រុមនីមួយៗនឹងធ្វើសកម្មភាពពិសេសនេះស្របទៅតាមតម្រូវការ ចំណាប់អារម្មណ៍ និងរបៀបរៀនរបស់ពួកគេនៅក្នុងពេលដំណាលគ្នារយៈពេល៣០ នាទីនៅរាល់ថ្ងៃសិក្សា។ សកម្មភាពនេះគួរតែត្រូវបានគ្រោងទុករួចជាស្រេចមុនពេលបង្រៀនក្នុងសប្តាហ៍នីមួយៗ ។
3. **ការកំណត់ពីសកម្មភាពនិងសម្ភារៈ:** កិច្ចតែងការបង្រៀនបន្ថែមនឹងជួយគ្រូបង្រៀនគ្រោងសកម្មភាពសំខាន់ៗនិងសម្ភារៈដែលនឹងត្រូវយកទៅប្រើប្រាស់លើការបង្រៀន និងរៀន ។ សកម្មភាពក្នុងន័យនេះត្រូវបានសង្ខេបនៅក្នុង**ឯកសារចែក ៣.៤.៦**។

# កិច្ចតែងការបង្រៀនបន្ថែម

សេចក្ដីណែនាំ: សូមបំពេញចន្លោះមានស្រាប់ក្នុងកិច្ចតែងការបង្រៀនបន្ថែមខាងក្រោមនេះ ។ កិច្ចតែងការនេះគួរតែត្រូវបានបំពេញ**ប្រចាំសប្ដាហ៍** ហើយត្រូវមានបញ្ជាក់ពីសកម្មភាពពិសេសទាក់ទងនឹងសកម្មភាពអំណាននិងសំណេរដែលអ្នកបានគ្រោងធ្វើជាមួយក្រុមកម្រិតសមត្ថភាពទាំង៤នៅក្នុងថ្នាក់រៀនរបស់អ្នក។ សកម្មភាពនីមួយៗត្រូវគ្រោងប្រើរយៈពេលប្រហែល២០ ទៅ៣០នាទីក្នុងកំឡុងពេលរៀនភាសាខ្មែរ។

| | | | |
|---|---|---|---|
| ខែ | ____________________ | សប្ដាហ៍: | ☐ 1 ☐ 2 ☐ 3 ☐ 4 |
| ថ្នាក់: | _____ | សាលារៀន: | ________________ |
| ឈ្មោះគ្រូ: | ____________________ | ឆមាស: | ☐ ឆមាសទី១ ☐ ឆមាសទី២ |

សកម្មភាពពង្រឹងអំណានដែលគ្រោងសម្រាប់:

| ឈ្មោះក្រុម: __________ (ឧទា. ក្រុមខ្លា, ក្រុមពណ៌លឿង ។ល។) | ក្រុមកម្រិត ☐ ក ☐ ខ ☐ គ ☐ ឃ | ថ្ងៃអនុវត្តសកម្មភាព? ☐ច ☐អ ☐ព ☐សុ☐ស |
|---|---|---|

| | | |
|---|---|---|
| ឈ្មោះសកម្មភាព: ______________________ <br><br> ទីកន្លែងសិក្សា: <br> ☐ កៀនអំណាន <br> ☐ កៀនសិក្សាពាក្យ <br> ☐ កៀនបណ្ណាល័យ <br> ☐ ផ្សេងៗ: <br> _______________ | ការពិពណ៌នាសកម្មភាព: | |
| សម្ភារៈត្រូវការ | ☐ ផាប់ប្លែត | ☐ ល្បែងមូសិកទន្ត និង |

| | | |
|---|---|---|
| (សូមធិក សម្ភារៈដែលត្រូវការ សម្រាប់ធ្វើសកម្មភាព សម្រាប់ក្រុមនេះ) | ☐ ក្រដាស់កិច្ចការផ ប្រឡេះ<br>☐ ល្បែងឡូតូ<br>☐ ល្បែងវេវចនៈសព្ទ<br>☐ ល្បែងបដិសព្ទ<br>☐ ល្បែងសទិសសព្ទ | ត្រីសព្ទ<br>☐ សៀវភៅលំហាត់ ផាត់ពណ៌<br>☐ សៀវភៅរឿងខ្លីៗ<br>☐ ក្រដាស់ A4<br>☐ ក្ងល់ទៀន /ខ្មៅដៃ ពណ៌<br>☐ ផ្សេងៗ: __________ |

ឈ្មោះក្រុម: _____________ (ឧទា. ក្រុមខ្លា, ក្រុមពណ៌លឿង ។ល។)

ក្រុមកម្រិត
☐ ក ☐ ខ ☐ គ ☐ ឃ

ថ្ងៃអនុវត្តសកម្មភាព?
☐ច ☐អ ☐ព ☐សុ☐ស

| | | |
|---|---|---|
| ឈ្មោះសកម្មភាព:<br>__________________________<br><br>ទីកន្លែងសិក្សា:<br>☐ កៀនអំណាន<br>☐ កៀនសិក្សាពាក្យ<br>☐ កៀនបណ្ណាល័យ<br>☐ ផ្សេងៗ:<br>_________________ | ការពិពណ៌នាសកម្មភាព: | |
| សម្ភារៈត្រូវការ<br>(សូមធិក សម្ភារៈដែលត្រូវការ សម្រាប់ធ្វើសកម្មភាព សម្រាប់ក្រុមនេះ) | ☐ ថាប់ប្លែត<br>☐ ក្រដាស់កិច្ចការផ ប្រឡេះ<br>☐ ល្បែងឡូតូ<br>☐ ល្បែងវេវចនៈសព្ទ<br>☐ ល្បែងបដិសព្ទ<br>☐ ល្បែងសទិសសព្ទ | ☐ ល្បែងមូសិកទន្ត និង ត្រីសព្ទ<br>☐ សៀវភៅលំហាត់ ផាត់ពណ៌<br>☐ សៀវភៅរឿងខ្លីៗ<br>☐ ក្រដាស់ A4<br>☐ ក្ងល់ទៀន /ខ្មៅដៃ |

| | | |
|---|---|---|
| | | ពណ៌<br>☐ ផ្សេងៗ: __________ |

| | | |
|---|---|---|
| ឈ្មោះក្រុម: ______________<br>(ឧទា. ក្រុមខ្លា, ក្រុមពណ៌លឿង ។ល។) | ក្រុមកម្រិត<br>☐ ក ☐ ខ ☐ គ ☐ ឃ | ថ្ងៃអនុវត្តសកម្មភាព?<br>☐ច ☐អ ☐ព ☐សុ☐ស |

| | | |
|---|---|---|
| ឈ្មោះសកម្មភាព:<br>____________________________<br><br>ទីកន្លែងសិក្សា:<br>☐ កៀនអំណាន<br>☐ កៀនសិក្សាពាក្យ<br>☐ កៀនបណ្ណាល័យ<br>☐ ផ្សេងៗ:<br>___________________ | ការពិពណ៌នាសកម្មភាព: | |
| សម្ភារៈត្រូវការ<br>(សូមធិក សម្ភារៈដែលត្រូវការ សម្រាប់ធ្វើសកម្មភាព សម្រាប់ក្រុមនេះ) | ☐ ថាប់ប្លែត<br>☐ ក្រដាស់កិច្ចការផ ប្រឡេះ<br>☐ ល្បែងឡូតូ<br>☐ ល្បែងវេវចនៈសព្ទ<br>☐ ល្បែងបដិសព្ទ<br>☐ ល្បែងសទិសសព្ទ | ☐ ល្បែងមូសិកទន្ត និង ត្រីសព្ទ<br>☐ សៀវភៅលំហាត់ ផាត់ពណ៌<br>☐ សៀវភៅរឿងខ្លីៗ<br>☐ ក្រដាស់ A4<br>☐ ក្លល័រទៀន /ខ្មៅដៃ ពណ៌<br>☐ ផ្សេងៗ: __________ |

| | | |
|---|---|---|
| ឈ្មោះក្រុម: ______________<br>(ឧទា. ក្រុមខ្លា, ក្រុមពណ៌លឿង ។ល។) | ក្រុមកម្រិត<br>☐ ក ☐ ខ ☐ គ ☐ ឃ | ថ្ងៃអនុវត្តសកម្មភាព?<br>☐ច ☐អ ☐ព ☐សុ☐ស |

<table>
<tr>
<td>ឈ្មោះសកម្មភាព:<br>__________________________<br><br>ទីកន្លែងសិក្សា:<br>☐ កៀនអំណាន<br>☐ កៀនសិក្សាពាក្យ<br>☐ កៀនបណ្ណាល័យ<br>☐ ផ្សេងៗ:<br>__________________</td>
<td colspan="2">ការពិពណ៌នាសកម្មភាព:</td>
</tr>
<tr>
<td>សម្ភារៈត្រូវការ<br>(សូមធិក សម្ភារៈដែលត្រូវការសម្រាប់ធ្វើសកម្មភាព សម្រាប់ក្រុមនេះ)</td>
<td>☐ ថាប់ប្លែត<br>☐ ក្រដាស់កិច្ចការផ ប្រឡោះ<br>☐ ល្បែងឡូតូ<br>☐ ល្បែងវេវចនៈសព្ទ<br>☐ ល្បែងបដិសព្ទ<br>☐ ល្បែងសទិសសព្ទ</td>
<td>☐ ល្បែងមូសិកទន្ត និងត្រីសព្ទ<br>☐ សៀវភៅលំហាត់ផាត់ពណ៌<br>☐ សៀវភៅរឿងខ្លីៗ<br>☐ ក្រដាស់ A4<br>☐ កូល័រទៀន /ខ្មៅដៃពណ៌<br>☐ ផ្សេងៗ: __________</td>
</tr>
</table>

## ឯកសារចែក ៣.៤.៦: សកម្មភាពជាក់ស្តែងប្រើប្រាស់សម្រាប់របៀបរៀនផ្សេងៗ

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
|---|---|---|
| **ការប្រើកាយវិការ ឬចលនា**<br>សិស្សដែលមានរបៀបរៀនតាមការប្រើកាយវិការ ឬចលនា អាចរៀនបានយ៉ាងពូកែ និងឆាប់រហ័សលុះត្រាតែមានការរៀន និងបង្រៀនពាក់ព័ន្ធនឹងការធ្វើសកម្មភាព ដូចជា៖ ការរំកិល ឬកាន់វត្ថុដែលត្រូវរៀននោះតែម្តង។ ពួកគេចូលចិត្តស្រាវជ្រាវ រៀន ឬធ្វើ នូវសកម្មភាពទាំងឡាយណាដែលភាគច្រើនធ្វើនៅខាងក្រៅថ្នាក់ ដោយជារឿយៗមានដូចជា៖ កីឡា និងការសម្តែងសិល្បៈ។ ភាគច្រើនពួកគេតែងបញ្ចេញអារម្មណ៍របស់ខ្លួនមកក្រៅតាមរយៈកាយវិការតែម្តង ដូចជាការឱបថើប ឬការវាយតប់។ ក្រៅពីនេះ ពួកគេចូលចិត្តរៀននូវជំនាញថ្មីៗដោយខ្លួនឯងជាងទទួលការណែនាំ ឬបង្ហាញពីអ្នកដទៃ។ ពួកគេលំបាកទ្រាំទ្រក្នុងការអង្គុយយូរមួយកន្លែងហើយពិបាកក្នុងការអាន និងប្រកប។ | • អនុញ្ញាតឱ្យសិស្សសាកល្បងធ្វើអ្វីមួយមុននឹងអ្នកផ្តល់សេចក្តីណែនាំលម្អិត<br>• កុំកម្រិតអំពីទីតាំងសិក្សាទៅនឹងតុដែលសិស្សអង្គុយប្រចាំថ្ងៃ ។ អនុញ្ញាតឱ្យសិក្សា ទន្ទឹមនឹងការដើរចល័តចុះឡើងក្នុងថ្នាក់ ផ្តេកខ្លួនទៅនឹងកម្រាលឥដ្ឋ ផ្តេកខ្លួនទៅនឹងកៅអីវែង ។<br>• ប្រើប្រាស់ទីតាំងក្រៅថ្នាក់សម្រាប់ឱកាសសិក្សាបន្ថែម<br>• បង្រៀនបញ្ញត្តិអប់រំតាមរយៈប្រើប្រាស់ល្បែងសិក្សា និងការងារគម្រោង ។<br>• ឱ្យសិស្សធ្វើបទបង្ហាញដើម្បីបង្ហាញពីការយល់ដឹងពីបញ្ញត្តិ និងបំណិន ។<br>• លើកទឹកចិត្តឱ្យប្រើប្រាស់ចលនារាងកាយពេលកំពុងសិក្សា សួរសំណួរសិស្សខណៈពេលកំពុងដើរ ។<br>• ឱ្យសិស្សសម្រាកឱ្យបានញឹកញាប់ | • ផ្តល់សម្ភារៈសិក្សាដែលអាចអនុវត្តជាក់ស្តែង ដូចជា ក្តារខៀន ដុំសម្រាប់រៀបជារូបរាងអ្វីមួយ ប្រស្នាផែនទី ដីឥដ្ឋសូនរូប បណ្តល្បែងល្បែងដែលផ្នែករបស់វាចល័តបាន ក្បាច់ និងក្តាររៀបរូបធរណីមាត្រ (ក្តារបួនជ្រុងដែលមានគ្រិតប្រើប្រាស់សម្រាប់បង្រៀនទ្រង់ទ្រាយ និងបញ្ញត្តិធរណីមាត្រ) |

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
|---|---|---|
| **ការមើល**<br>សិស្សដែលមានរបៀបរៀនតាមការមើល អាចរៀនបានយ៉ាងល្អ និងឆាប់រហ័សលុះត្រាតែមានការរៀន និងបង្រៀនបង្ហាញឱ្យឃើញនៅពីមុខពួកគេតែម្តង ហើយរូបភាពទាំងនោះត្រូវបានរក្សាទុកក្នុងខួរក្បាលតែម្តង។ ពួកគេជារឿយៗចូលចិត្តអានហើយសរសេរអក្សរស្អាត។ ពួកគេក៏ជាអ្នកដែលចូលចិត្តស្វែងយល់ពីឫសគល់នៃបញ្ហា រៀបចំចាត់ចែងច្បាស់លាស់ និងមានចំណាប់អារម្មណ៍ខ្លាំងលើពណ៌ ឬទ្រង់ទ្រាយវត្ថុផ្សេងៗ។ ពួកគេតែងជួបការលំបាកពេលគ្រូប្រាប់ការណែនាំផ្ទាល់មាត់ និងងាយទទួលការរំខានពីសំឡេងផ្សេងៗ។ ពួកគេចំណាំមុខអ្នកដែលគេស្គាល់ជាងឈ្មោះ។ ពួកគេចូលចិត្តសម្លឹងមើលភ្នែកដៃគូសន្ទនាដើម្បីពង្រឹងការផ្តោតអារម្មណ៍។ | • ឱ្យសិស្សស្វែងយល់ពីរូបក្រាហ្វិក/ដ្យាក្រាមងាយៗ<br>• សរសេរពន្យល់សេចក្តីណែនាំ<br>• ប្រើសម្ភារៈជំនួយចក្ខុពេលបង្រៀន ដូចជារូបភាព តារាង ដ្យាក្រាម ផែនទី គ្រោងប្លង់ បណ្ណរូបភាព ដុំសម្រាប់រៀបជារូបរាងអ្វីមួយ<br>• បង្ហាញកិច្ចការដោយទិដ្ឋភាពជាក់ស្តែង<br>• បង្ហាញលំនាំបង្រៀនជារូបភាពជាក់ស្តែងទាក់ទងនឹងការបង្រៀនប្រកបពាក្យ វាក្យសព្ទ វេយ្យាករណ៍ និងវណ្ណយុត្តិ ។<br>• រៀបចំព័ត៌មានដោយប្រើកូដពណ៌ ។<br>• ជជែកជាមួយសិស្សមួយទល់មួយ និងទំនាក់ទំនងគ្នាដោយប្រើភ្នែក<br>• នៅពេលផ្តល់សេចក្តីណែនាំផ្ទាល់មាត់ ឱ្យសិស្សសួរសំណួរបញ្ជាក់ឡើងវិញពេលមិនទាន់យល់ច្បាស់ ។<br>• លើកទឹកចិត្តសិស្សឱ្យសរសេរកំណត់ត្រាឱ្យបានច្រើន និងរៀបចំព័ត៌មាននៅ | • ល្បែង និងលំហាត់ដែលមានរូបភាព<br>• ល្បែង និងលំហាត់ដែលដាក់កូដពណ៌ ។<br>• សម្ភារៈជំនួយចក្ខុដូចជា បណ្ណរូបភាព<br>• ផ្ទាំងប៉ុស្ទ័រ<br>• លំហាត់ដែលមានសេចក្តីណែនាំជាដ្យាក្រាម ព្រួញ ឬខ្សែបន្ទាត់ ។<br>• បញ្ញត្តិដែលពន្យល់ដោយប្រើដ្យាក្រាម (ឧទា. បង្កើតដ្យាក្រាមល្បះមួយ ) |

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
| --- | --- | --- |
| | លើក្រដាស និងប្រើប្រាស់វត្ថុផ្សេងៗ ។<br>• ផ្តល់ទីកន្លែងដែលស្ងាត់ស្ងៀម ស្អាត ដើម្បីកាត់បន្ថយការរំខានឱ្យបានច្រើនតាមដែលអាចធ្វើបាន ។ | |
| **ការនិយាយ និងការស្តាប់**<br>ភាសានិយាយគឺជាទម្រង់បឋមសម្រាប់ផ្លាស់ប្តូរព័ត៌មានសម្រាប់សិស្សដែលមានរបៀបរៀនតាមរយៈការនិយាយ និងស្តាប់។ ពួកគេអាចរៀនបានល្អ និងឆាប់រហ័សតាមរយៈការស្តាប់ និងការនិយាយ។ ពួកគេតែងតែនិយាយច្រើនជាងមនុស្សទូទៅ រស់រាយរាក់ទាក់ ចូលចិត្តស្តាប់រឿងនិទាន និងរឿងកំប្លែង យល់ដឹងមេរៀនតាមរយៈការពន្យល់ផ្ទាល់មាត់ទៅកាន់ពួកគេ។ ពួកគេភាគច្រើនមានទំនោរទៅលើសកម្មភាពតន្ត្រី និងសិស្បៈ ។<br><br>សិស្សប្រភេទនេះមួយចំនួនអានយឺត លំបាកក្នុងការសរសេរ និងលំបាកយល់ដឹងសេចក្តីណែនាំតាមការសរសេរពន្យល់។ពួកគេពុំអាចនៅស្ងៀមស្ងាត់បានយូរទេ។ ពួកគេចាំឈ្មោះ និងសំឡេងអ្នកដែលគេជួបបានយ៉ាងល្អ តែពុំសូវចាំមុខមាត់នោះឡើយ។ ពួកគេជារឿយៗចូលចិត្តច្រៀង និងអានខ្សិបៗទៅកាន់ខ្លួនឯង។ | • ចូលចិត្តការសិក្សាតាមរយៈការស្តាប់<br>• ចូលចិត្តកិច្ចការដែលពាក់ព័ន្ធនឹងការនិយាយ/សម្តែងការយល់ឃើញ<br>• លេងល្បែងពាក្យ និងប្រើពាក្យចួនដើម្បីរៀនភាសា<br>• ឱ្យកុមារអានឮៗ បើទោះបីជាសិស្សនៅម្នាក់ឯងក៏ដោយ និងអានអត្ថបទដោយប្រើម្រាមដៃចង្អុលនាំមុខ ។<br>• អនុញ្ញាតឱ្យសិស្សពន្យល់បញ្ញត្តិដោយផ្ទាល់មាត់ និងផ្តល់របាយការណ៍ផ្ទាល់មាត់ ។<br>• ឱ្យកុមារចងចាំព័ត៌មានដោយឱ្យពួកគេគ្រាប់តាមឮៗ ។<br>• ផ្តល់កិច្ចការឱ្យធ្វើជាក្រុមតូច និងក្រុមធំ ។ | • សិក្សាជាក្រុមនិងពិភាក្សាអំពីអ្វីមួយ<br>• ត្រូវមានឧបករណ៍ថតសំឡេងមួយ<br>• ការថតសំឡេងការឧទ្ទេស ការបង្រៀនសិស្សមួយទល់មួយ ការសិក្សាជាក្រុម (ឱក្រុមសិស្សពិនិត្យសិក្សាឡើងវិញអំពីសំឡេងដែលបានថត)<br>• អត្ថបទ/សៀវភៅចេះនិយាយ (ក្នុងថាប់ប្លែត)<br>• ការសរសេរតាមអាន<br>• អានសំណួរឱ្យឮៗ<br>• ពិភាក្សាអំពីបញ្ហាឱ្យឮៗ<br>• សិក្សាតាមការចូលរួមក្នុងការពិភាក្សា |

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
|---|---|---|
| | • អានឱ្យឮៗទៅកាន់កុមារតូចៗឱ្យបានញឹកញាប់ ។<br>• ផ្តល់ឧករណ៍ថតសម្លេងផ្ទាល់ខ្លួនសម្រាប់កុមារប្រើប្រាស់ដើម្បីកត់ត្រាកំណត់សម្គាល់ ឬសំណួរផ្សេងៗ ។<br>• ប្រើ ចង្វាក់ ចុងចួន និងចម្រៀងដើម្បីពង្រឹងការសិក្សា ។ | ក្នុងថ្នាក់ និងការជជែកដេញដោល<br>• ថ្លែងសុន្ទរកថា និងធ្វើបទបង្ហាញ<br>• បង្កើតស្ករសំឡេងដើម្បីជំនួយដល់ការចាំអ្វីមួយ<br>• ប្រើប្រាស់សទិសភាព (ភាពស្រដៀងគ្នា) ផ្ទាល់មាត់ និងការនិទានរឿងដើម្បីបង្ហាញពីគំនិតសំខាន់<br>• អានសេចក្តីពន្យល់ឱ្យឮៗ<br>• រៀនពីលំដាប់លំដោយនៃជំហានអ្វីមួយ សរសេរចេញជាល្បះ រួចអានល្បះទាំងនោះឱ្យឮៗ<br>• សូត្រផ្ទាល់មាត់<br>• ការពិភាក្សាអំពីគំនិតយោបល់ |
| **ការផ្តោតតាមតែអាម្មណ៍ផ្ទាល់ខ្លួន**<br>កុមារដែលផ្តោតតែលើអារម្មណ៍ផ្ទាល់ខ្លួនមានចរិកខ្វល់ខ្វាយឬការពារសកម្មភាពរបស់ខ្លួនឯង ចូលចិត្តទី | • ចូលចិត្តធ្វើការតែម្នាក់ឯងជាជាងការងារក្រុម<br>• ចូលចិត្តអានស្ងាត់ៗជាជាងអានឮៗ | • សម្ភារៈស្វ័យសិក្សា<br>• សៀវភៅសម្រាប់អំណានបែប |

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
| --- | --- | --- |
| កន្លែងនិងពេលវេលាឯកជន រីករាយនៅម្នាក់ឯង ធុញទ្រាន់នៅពេលធ្វើការឬនៅជាមួយក្រុមសិស្សផ្សេងៗ ។ ពួកគេធ្វើសកម្មភាពដោយប្រុងប្រយ័ត្នពេលជួបមនុស្សម្នា ។ ពួកគេមិនបង្ហាញអារម្មណ៍និងចូលចិត្តនៅស្ងៀមស្ងាត់ ។ ពួកគេមិនចែករំលែកនូវការគិត អារម្មណ៍ឯកជនរបស់ពួកគេទេ ហើយពួកគេមានមិត្តភក្តិជិតស្និទ្ធតិចតួចប៉ុណ្ណោះ ។ ពួកគេយល់ថាសកម្មភាពបែបឆ្លុះបញ្ចាំងមានសារៈសំខាន់ ។ ជាមនុស្សដែលផ្តោតអារម្មណ៍បានល្អនិងគិតស៊ីជម្រៅ ។ ពូកែស្រូបយកគំនិតយោបល់ ។ ពួកគេចេះកំណត់អំពីចំណាប់អារម្មណ៍របស់ខ្លួន ប៉ុន្តែស្វែងយល់បានស៊ីជម្រៅលើផ្នែកដែលគេចាប់អារម្មណ៍ ។ ពួកគេជ្រួលច្រាលក្នុងចិត្តបើមិនមានពេលគ្រប់គ្រាន់នៅម្នាក់ឯង ឬស្ងៀមស្ងាត់ | • ទំនាក់ទំនងបានល្អបំផុតគឺមួយទល់មួយ<br>• គិតដោយប្រយ័ត្នប្រយែងមុននឹងនិយាយ | បុគ្គល<br>• ឧបករណ៍សិក្សាចល័ត (ថាប់ប្លេត) |
| **ការចូលចិត្តធ្វើការជាមួយក្រុមមនុស្ស**<br>សិស្សដែលមានរបៀបរៀនតាមការចូលចិត្តធ្វើការជាមួយក្រុមមនុស្សគឺជាសិស្សដែលចូលចិត្តសេពគបជាមួយអ្នកឯទៀត ។ ពួកគេរីករាយនៅជាមួយមនុស្សម្នា និងបង្ហាញពីភាពស្វាហាប់និងសំឡេងកងរំពង ។ ពួកគេទំនាក់ទំនងគ្នាដោយក្តីរំភើប និងរីករាយជាមួយមនុស្សគ្រប់គ្នាយ៉ាងជិតស្និទ្ធ ។ ពួកគេចូលរួមធ្វើសកម្មភាពច្រើន និង | • ចូលចិត្តធ្វើការក្រុម<br>• ចូលចិត្តអានឮជាជាងអានស្ងាត់<br>• ចាប់អារម្មណ៍ព្រឹត្តការណ៍ខាងក្រៅ<br>• ចូលចិត្តការទំនាក់ទំនងផ្ទាល់មាត់ជាជាងបែបសរសេរ ។<br>• ឆ្លើយតបបានលឿន | -- |

| ចំណូលចិត្តសិក្សារបស់សិស្ស | សកម្មភាពជាក់ស្តែងសម្រាប់បង្រៀន | សម្ភារៈ និងសកម្មភាព |
|---|---|---|
| មានចំណាប់អារម្មណ៍ច្រើនផ្នែក ។ ពួកគេមានមិត្តភក្តិច្រើន និងនិយាយគ្នាក្នុងរយៈពេលយូរ ។ ពួកគេទទួលបានថាមពលពីមនុស្សនៅជុំវិញ ហើយពួកគេនឹងមានភាពឯកោ និងច្រាសច្រាល់នៅពេលគ្មានមនុស្សនៅក្បែរ ។ ពួកគេបង្កើតទំនាក់ទំនងជាមួយអ្នកឯទៀតជាបន្តបន្ទាប់ និងចែករំលែកពីព័ត៌មានផ្ទាល់ខ្លួនយ៉ាងងាយស្រួលជាមួយគ្នា ។ | | |

- **របៀបរៀនដែលលេចធ្លោទី១ និងទី២:** អ្នកចិត្តវិទ្យាយល់ស្របថាស្ទើរតែគ្មាននរណាម្នាក់មានរបៀបរៀនតែមួយនោះទេ ។ គេអាចធ្វើចំណាត់ប្រភេទរបៀបរៀនតែមួយបាន ប៉ុន្តែមនុស្សមានលក្ខណៈពិសេសផ្សេងទៀតដែលអាចបង្កើតជារបៀបរៀនផ្សេងទៀត ឬពួកគេមានរបៀបរៀនទី២ដែលត្រូវនឹងពួកគេជាងរបៀបរៀនផ្សេងៗទៀត ។ ឧទាហរណ៍ សិស្សម្នាក់អាចជាអ្នកចូលចិត្តរៀនតាមការមើល ហើយក៏មានរបៀបនៃការរៀនបែបស្តាប់និងនិយាយខ្លះៗ ប៉ុន្តែពួកគេគ្មានរបៀបរៀនបែបធ្វើចលនានោះទេ ។

- **របៀបរៀនបែបធ្វើសកម្មភាពឬចលនាលេចធ្លោជាងគេនៅការអប់រំថ្នាក់ដំបូង:** អ្នកចិត្តវិទ្យាមួយចំនួនលើកឡើងថាកុមារទាំងអស់គឺមានរបៀបរៀនបែបធ្វើសកម្មភាពឬចលនាលេចធ្លោជាងគេរហូតដល់ថ្នាក់ទី២ និងទី៣ ប៉ុន្តែពួកគេនឹងដុះដាលរបៀបរៀនផ្សេងៗទៀតនៅពេលថ្នាក់កាន់តែខ្ពស់ ឬការសិក្សារបស់ពួកគេកាន់តែល្អិតល្អន់ទៅ ។

## ឯកសារចែក ៣.៥.១: ការស្វែងយល់ពីមូលហេតុដែលយើងធ្វើការវាយតម្លៃ

### សេចក្តីពន្យល់

**ហេតុអ្វីបានជាការវាយតម្លៃជារឿយៗធ្វើទៅដោយពុំមានប្រសិទ្ធភាព?** មានមូលហេតុជាច្រើនដែលយើងធ្វើការវាយតម្លៃ ។ ទោះបីជាយ៉ាងណា ជាញឹកញាប់ គ្រូបានធ្វើការវាយតម្លៃសិស្សដោយមិនដឹងពីមូលហេតុដែលខ្លួនត្រូវធ្វើការវាយតម្លៃនោះទេ ។ មានករណីជាច្រើនដែលគ្រូបង្រៀនធ្វើការវាយតម្លៃតាមតែអ្វីដែលថ្នាក់លើប្រាប់ឱ្យពួកគេឱ្យធ្វើ ដែលជាលទ្ធផលនាំទៅដល់ការប្រើប្រាស់ទិន្នន័យវាយតម្លៃដែលគ្មានប្រសិទ្ធភាព ។

*ស្តង់ដាអំណានដែលបានផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា មានបំណងជួយគ្រូបង្រៀនរៀបចំផែនការវាយតម្លៃសិស្សឱ្យប្រសើរឡើង និងប្រើប្រាស់ទិន្នន័យវាយតម្លៃដើម្បីកែសម្រួលវិធីសាស្ត្របង្រៀនឡើងវិញ ក៏ដូចជាកំណត់រកសិស្សដែលជួបបញ្ហាក្នុងការរៀនអំណាន ។ ដូច្នោះ ឯកសារនេះផ្តល់ជាមធ្យោបាយមួយសម្រាប់ ការវាយតម្លៃពង្រឹងការយល់ដឹង (Formative Assessment) របស់សិស្សនៅក្នុងថ្នាក់រៀន ។*

***ការយល់ដឹងពីគោលបំណងក្នុងការវាយតម្លៃ:*** មុននឹងធ្វើការវាយតម្លៃ សំខាន់អ្នកត្រូវយល់ពីគោលបំណងរបស់អ្នកក្នុងការវាយតម្លៃ ។ ផ្អែកលើគោលបំណង គ្រូបង្រៀនភាគច្រើនត្រូវធ្វើការវាយតម្លៃមួយក្នុងចំណោមការវាយតម្លៃពីរប្រភេទ ។ ប្រភេទនៃការវាយតម្លៃទាំងនេះត្រូវកំណត់ដូចខាងក្រោម:

**ប្រភេទនៃការវាយតម្លៃសិស្សដែលប្រើជាទូទៅក្នុងថ្នាក់រៀន:**[5]

***ការវាយតម្លៃពង្រឹងការយល់ដឹងរបស់សិស្ស:*** ការវាយតម្លៃបែបនេះមានលក្ខណៈ: ជាការវាយតម្លៃបែបផ្លូវការ និងមិនផ្លូវការដោយគ្រូបង្រៀនក្នុងកំឡុងដំណើរការបង្រៀនដើម្បីកែសម្រួលសកម្មភាពរៀននឹងបង្រៀនឈានទៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

---

5 https://www.google.com/search?client=safari&rls=en&q=Definition+of+Formative+Assessment&ie=UTF-8&oe=UTF-8#q=definition+of+summative+assessment

*ការវាយតម្លៃបែបសរុប:* ការវាយតម្លៃប្រភេទនេះសំដៅលើការវាយតម្លៃសិស្ស ដើម្បីរកលទ្ធផលសិក្សាចុងក្រោយ ។

**សូមសាកល្បងធ្វើលំហាត់ដែលផ្តល់ជូនខាងក្រោម ដោយផ្អែកលើការយល់ដឹងពីគោលគំនិតដែលបានអធិប្បាយខាងលើ ។ សូមពិភាក្សាចម្លើយរបស់អ្នកជាមួយសមាជិកក្រុម និងអ្នកសម្របសម្រួល។**

## លំហាត់: ការវាយតម្លៃពង្រឹងការយល់ដឹង ឬ ការវាយតម្លៃបែបសរុប?

***សេចក្តីណែនាំ:*** *ចូរអានគោលបំណងនៃការវាយតម្លៃនីមួយៗខាងក្រោម និងកំណត់ថា តើវាជាការវាយតម្លៃបែបពង្រឹងការយល់ដឹង ឬការវាយតម្លៃបែបសរុប ដោយផ្អែកលើការយល់ដឹងលើនិយមន័យដែលបានពិភាក្សាខាងលើ។ ចូរសរសេរចម្លើយនៅក្នុងជួរឈរខាងស្តាំដៃ។*

| គោលបំណង ឬ ការប្រើប្រាស់ | ប្រភេទនៃការវាយតម្លៃអ្វី? |
|---|---|
| ១. គ្រូចង់ដឹងថាសិស្សណាដែលមិនទាន់យល់ខ្លឹមសារមេរៀនដើម្បីផ្តល់នូវជំនួយបន្ថែម។ | ________________ |
| ២. គ្រូចង់ដឹងថាសិស្សណាត្រូវឡើងថ្នាក់និងត្រួតថ្នាក់សម្រាប់ឆ្នាំសិក្សាថ្មី។ | ________________ |
| ៣. គ្រូចង់ដឹងថាកម្រិតស្តង់ដាអំណានមួយណាដែលសិស្សយល់មិនច្បាស់ដើម្បីបង្រៀនឡើងវិញ។ | ________________ |
| ៤ .ក្រសួងចង់ដឹងពីលទ្ធផលសិក្សាជាមធ្យមរបស់សិស្សនៅចុងឆ្នាំសិក្សា | ________________ |
| ៥. គ្រូចង់ដឹងថាចំណុចអ្វីដែលសិស្សយល់មិនច្បាស់ដើម្បីស្វែងរកល្បែង | |

| | |
|---|---|
| សិក្សាមកពង្រឹងការយល់ដឹងរបស់គេ។ | ______________________ |
| ៦ .គ្រូចង់ដឹងពីផ្នែកណាមួយនៃផែនការមេរៀនរបស់គាត់មានដំណើរការល្អ និងមិនល្អ ដើម្បីកែសម្រួលសម្រាប់ឆ្នាំសិក្សាក្រោយ។ | ______________________ |

## ឯកសារចែក ៣.៥.២ក: ស្វែងយល់ពីបំណិនអំណានគន្លឹះទាំង៥

សេចក្តីពន្យល់: ដើម្បីប្រើប្រាស់កម្រិតស្តង់ដាដែលបានផ្តល់នៅក្នុងសៀវភៅស្តង់ដាអំណានឱ្យមានប្រសិទ្ធភាព គ្រូបង្រៀនគួរដឹងអំពីបំណិនអំណានគន្លឹះទាំង៥ដែលបង្ហាញក្នុងកម្រិតស្តង់ដានីមួយៗ ។ ការកំណត់បំណិនទាំងនោះផ្អែកទៅលើការស្រាវជ្រាវអន្តរជាតិដែលទទួលស្គាល់ដោយក្រសួង ។ ការកំណត់នៃបំណិននីមួយៗទាំងនោះត្រូវបានផ្តល់ដូចខាងក្រោម៖

(1) ការស្គាល់សូរ –គឺសំដៅការបង្រៀនដើម្បីជួយឱ្យសិស្សមានសមត្ថភាពកំណត់ ប្រើប្រាស់ និងញែកសូរក្នុងពាក្យ។
ឧទាហរណ៍: សិស្សអាចកំណត់សូរតួអក្សរក្នុងពាក្យ " កា" (ក និង ស្រះអា)។

(2) ការស្គាល់តួអក្សរ និងសូរ –គឺសំដៅដល់ការបង្រៀនដែលជួយដល់អ្នកអាន (សិស្ស) យល់ និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរ និងសូរ ។
ឧទាហរណ៍: សិស្សអាចប្រាប់គ្រូថារូបភាពនៃពាក្យ "កា" មានសូរតួអក្សរ "ក"។

(3) ការចេះអានស្ទាត់ –គឺសំដៅលើការបង្រៀនដែលជួយពង្រឹងដល់សមត្ថភាពអានឮដោយមានល្បឿនច្បាស់លាស់ និងការបង្ហាញគំនិតត្រឹមត្រូវ។
ឧទាហរណ៍: សិស្សអាចអានពាក្យ ឃ្លា ឬល្បះឮខ្លាំងៗ

(4) ការចេះវាក្យសព្ទ –សំដៅការបង្រៀនដើម្បីបង្កឱ្យមានចំណេះដឹងស្តីពីពាក្យ រាប់ទាំងពាក្យដែលនិយាយផ្ទាល់មាត់ និងពាក្យសរសេរ។
ឧទាហរណ៍: សិស្សអាចអានពាក្យប្រើញឹកញាប់ដែលគ្រូសរសេរនៅលើក្តារខៀន ឬតាមរយៈការបង្ហាញបណ្ណពាក្យ ។

(5) ការអានដើម្បីយល់ន័យ – សំដៅការបង្រៀនដែលធ្វើឱ្យសិស្សមានសមត្ថភាពចូលរួម និងបញ្ចេញន័យដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។
ឧទាហរណ៍: សិស្សអាចប្រាប់គ្រូអំពីអត្ថន័យនៃល្បះដោយប្រើពាក្យសម្តីផ្ទាល់ខ្លួន។

# លំហាត់: តើមានបំណិនអំណានអ្វីខ្លះ?

*សេចក្ដីណែនាំ:* *សូមអានឧទាហរណ៍សកម្មភាពខាងក្រោមដែលគ្រូបង្រៀនប្រើដើម្បីបង្រៀនអំណាន រួចកំណត់រកបំណិនអំណានដោយបំពេញក្នុងកូឡោនខាងស្ដាំដៃ។*

| សកម្មភាពសិស្ស | បំណិនអំណានគន្លឹះ? |
|---|---|
| 1. នៅពេលសិស្សឮពាក្យចំនួនពីរ ពួកគេអាចប្រាប់បានថា តើពាក្យទាំងពីរនោះមានសូរចួនឬអត់? | |
| 2. សិស្សត្រូវស្វែងរកវេវចនសព្ទនៃពាក្យនីមួយៗដែលពួកគេបានអាន | |
| 3. នៅពេលដែលសិស្សអានល្បះដែលស្រង់ចេញពីសាច់រឿងមួយដែលមិនរៀបតាមលំដាប់លំដោយ ពួកគេអាចប្រាប់បានថាល្បះណាកើតមុន និងល្បះណាកើតបន្ទាប់ ។ល។ | |
| 4. នៅពេលដែលសិស្សឮពាក្យមួយ ពួកគេអាចប្រាប់ពីរបៀបប្រកបពាក្យនោះបានយ៉ាងត្រឹមត្រូវ | |
| 5. បន្ទាប់ពីអានរឿងខ្លីរួច សិស្សអាចរកចំណងជើងផ្សេងៗនៃសាច់រឿងតែនៅរក្សាខ្លឹមសារដដែល | |
| 6. សិស្សអាចអានកំណាព្យទាំងពីដើមដល់ចប់ដោយឮៗ | |

7. សិស្សត្រូវរកបដិសព្ទនៃពាក្យ ”មិត្ត” យ៉ាងតិចឱ្យបានពីរពាក្យ

_________________________

_________

8. នៅពេលឃើញរូបភាពខាងក្រោម ពួកគេអាចបំពេញតួអក្សរក្នុងចន្លោះខាងក្រោម:

_________________________

________



ម_ន់

**បំណិនអំណានដែលពាក់ព័ន្ធ**

ការស្គាល់ស្វរ- ការស្គាល់តួអក្សរ និងស្វរ- ការចេះវាក្យសព្ទ - ការចេះអានស្ទាត់ - ការអានដើម្បីយល់ន័យ

## ឯកសារចែក ៣.៥.២ខ: ការសង្ខេបបំណិនភាសាដែលគ្របដណ្តប់នៅក្នុងសៀវភៅស្តង់ដា

សេចក្តីពន្យល់: ក្រៅពីអំណាន សៀវភៅស្តង់ដាអំណានក៏បញ្ចូលសកម្មភាព សំណេរ និងបំណិនទាក់ទងផ្សេងទៀត ដែលរួមបញ្ចូលគ្នាបានគ្រប់ដណ្តប់ប្រហែល ៨០% ទៅ ៨៥%នៃកម្មវិធីសិក្សាភាសាខ្មែរទាំងមូល។ តារាងខាងក្រោមសង្ខេបអំពីបំណិនផ្សេងៗ ដែលគ្របដណ្តប់ក្នុងសៀវភៅស្តង់ដាអំណាន។

| បំណិនពាក់ព័ន្ធ | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ |
|---|---|---|---|
| **អំណាន** | | | |
| ការស្គាល់តួអក្សរ | ✓ | ✓ | ✓ |
| ការស្គាល់តួអក្សរ និងស្ទូរ | ✓ | ✓ | ✓ |
| ការចេះវាក្យសព្ទ | ✓ | ✓ | ✓ |
| ការចេះអានស្ទាត់ | ✓ | ✓ | ✓ |
| ការអានដើម្បីយល់ន័យ | ✓ | ✓ | ✓ |
| **សំណេរ** | | | |
| បំណិនសំណេរ | ✓ | ✓ | ✓ |
| ការបង្កើតល្បះ | | ✓ | ✓ |
| សរសេរតាមអាន | | ✓ | ✓ |
| តែងសេចក្តី | | | ✓ |
| • តែងកថាខណ្ឌ | | | ✓ |
| • តែងសេចក្តី | | | ✓ |
| **បំណិនផ្សេងៗ** | | | |
| បំណិនវេយ្យាករណ៍ | | | ✓ |

| | | | |
|---|---|---|---|
| • ផ្ទាក់ពាក្យ | | | ✓ |
| • វណ្ណយុត្ត | ✓ | ✓ | ✓ |
| • សញ្ញាបំប្លែងសំឡេង (មូសិកទន្ត និងត្រីសព្ទ) | ✓ | ✓ | ✓ |
| **បំណិនពាក្យ** | | | ✓ |
| • ពាក្យចូន | | | ✓ |
| • វេវចនសព្ទ-បដិសព្ទ- សទិសសព្ទ | | ✓ | ✓ |
| ការស្គាល់ហេតុ និងផល | | | ✓ |
| ការវិភាគតួអក្សរ | | | ✓ |
| បំណិននិយាយ[6] | ✓ | ✓ | ✓ |
| បំណិនស្តាប់[7] | ✓ | ✓ | ✓ |

[6] មិនបានបញ្ចូល

[7] មិនបានបញ្ចូល

## ឯកសារចែក ៣.៥.៣: ការស្វែងយល់ពីទម្រង់នៃសៀវភៅស្តង់ដាអំណាន

*សូមត្រួតពិនិត្យសេចក្តីពន្យល់នៃទំព័រគម្រូដកស្រង់ចេញពីសៀវភៅស្តង់ដាអំណាន និងពិភាក្សានូវសំណួរដែលលោកអ្នកឆ្ងល់ បន្ទាប់មកឆ្លើយសំណួរខាងក្រោម ។*

១ : សមត្ថភាពសិស្ស .ផ្នែកនេះបង្ហាញអំពីសមត្ថភាពអំណានដែលសិស្សត្រូវសម្រេចឱ្យបានក្នុងពេលសិក្សាតាមដំណាក់កាលនីមួយៗ ។

២ : បំណិនអំណាន .ផ្នែកនេះបង្ហាញអំពីបំណិនមួយក្នុងចំណោមបំណិនអំណានទាំង៥ដែលសិស្សត្រូវចេះ រួមមាន ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ ។

៣ : ខ្លឹមសារ .ផ្នែកនេះបង្ហាញពីខ្លឹមសារសង្ខេបដែលសិស្សត្រូវរៀនតាមដំណាក់កាលនីមួយៗ ដូចជា តួអក្សរ វណ្ណយុត្ត ។ល។



៤ : សកម្មភាពគំរូ .ផ្នែកនេះ ផ្តល់នូវកិច្ចការជាក់លាក់ឆ្លើយតបទៅនឹងសមត្ថភាពសិស្ស ។ បើសិស្សបំពេញកិច្ចការមួយឬច្រើនបានជោគជ័យ នោះមានន័យថាសិស្សទទួលបាននូវសមត្ថភាព ។

៥ : ឧបករណ៍វាយតម្លៃ .ផ្នែកនេះ: បង្ហាញពីឧបករណ៍តេស្តដែលមានក្នុងឧបសម្ព័ន្ធដែលគ្រូអាចប្រើប្រាស់ដើម្បីវាយតម្លៃសមត្ថភាពសិស្ស ។ ដោយផ្អែកទៅតាមបំណិន អំណានគឺមានទាំងតេស្ត សំណេរ និងផ្ទាល់មាត់ ។

៦ : ល្បែងសិក្សា .ផ្នែកនេះបង្ហាញអំពីល្បែងសិក្សាដែលគ្រូអាចប្រើប្រាស់ដើម្បីលើកកម្ពស់សមត្ថភាពសិស្ស ។

គម្រូឧទាហរណ៍ដកស្រង់ចេញពីសៀវភៅស្តង់ដាអំណានរបស់ក្រសួង

## លំហាត់: ការស្វែងយល់ពីសៀវភៅស្តង់ដា

*សេចក្តីណែនាំ: សូមអានសំណួរនីមួយៗខាងក្រោមក្នុងក្រុម រួចត្រួតពិនិត្យសៀវភៅស្តង់ដាអំណានដើម្បីស្វែងរកចម្លើយ ។*

1. តើមានប៉ុន្មានដំណាក់កាលនៅក្នុងសៀវភៅស្តង់ដាអំណានថ្នាក់ទី១? ថ្នាក់ទី២? ថ្នាក់ទី៣?

   ថ្នាក់ទី១ : __________ ថ្នាក់ទី២ : __________ ថ្នាក់ទី៣ : __________

2. តើដំណាក់កាលណាដែលវែងជាងគេនៅក្នុងសៀវភៅស្តង់ដាអំណានានីមួយៗ? និងដំណាក់កាលណាខ្លីជាងគេ?

   (វែងជាងគេ) ថ្នាក់ទី១: __________ ថ្នាក់ទី២: __________ថ្នាក់ទី៣: __________

   (ខ្លីជាងគេ) ថ្នាក់ទី១: __________ ថ្នាក់ទី២: __________ ថ្នាក់ទី៣: __________

3. តើមានតេស្តដំណាក់កាលប៉ុន្មាននៅក្នុងសៀវភៅស្តង់ដាអំណាននីមួយៗ? តើមានតេស្តផ្ទាល់មាត់ប៉ុន្មាននៅក្នុងសៀវភៅស្តង់ដាអំណាននីមួយៗ?

   (តេស្តដំណាក់កាល) ថ្នាក់ទី១: _______ ថ្នាក់ទី២: ________ ថ្នាក់ទី៣: ________

   (តេស្តផ្ទាល់មាត់) ថ្នាក់ទី១: ________ថ្នាក់ទី២: ________ ថ្នាក់ទី៣: _________

4. តើកម្មវិធីសុសវែរមានប៉ុន្មានមេរៀនដែលប្រើសម្រាប់បង្រៀនភាសាខ្មែរ?

   ______________________________________________

5. តើគេប្រើល្បែងសិក្សាឡូតូដើម្បីពង្រឹងបំណិនអំណានអ្វី ? តើអ្នកដឹងដោយរបៀបណា?________________________________________________________

6. សូមមើលស្តង់ដា៨ខ ក្នុងសៀវភៅស្តង់ដាថ្នាក់ទី២ តើបំណិនអ្វីដែលជាបំណិនសំខាន់សម្រាប់បណ្តុះឱ្យកុមារទទួលបាននៅក្នុងស្តង់ដានេះ? តើតេស្តអ្វីដែលសមស្របយកមកប្រើជាមួយស្តង់ដានេះ? តើអ្នកដឹងដោយរបៀបណា?

   ______________________________________________________________

# ឯកសារចែក ៣.៥.៤: ការប្រើឧបករណ៍វាយតម្លៃក្នុងសៀវភៅស្តង់ដាអំណាន

## គំរូតេស្តស្តង់ដាអំណាន(ថ្នាក់ទី១,ទំព័រ៩១)

ជំហាន ១: ចែកឯកសារតេស្តដល់សិស្សម្នាក់ៗ ដោយប្រើសន្លឹកអ៊ិតក៏បានឬ សន្លឹកថតចម្លងក៏បាន
ជំហាន ២: អានសេចក្តីណែនាំពីរបៀបប្រើតេស្តនីមួយៗ
ជំហាន ៣: បន្ទាប់ពីអានសេចក្តីណែនាំរួច ប្រគល់តេស្តដល់គ្រូបន្ទុកថ្នាក់។
ជំហាន ៤: ធ្វើតារាងលទ្ធផលតេស្តដោយបំពេញក្នុងប្រអប់តូចផ្នែកខាងស្តាំ។

៤.ង៖ សិស្សអាចអានពាក្យដោយចំណាំដែលមានប្រើមូសិកទន្ត(៉) និងត្រីស័ព្ទ(៊)ជាមួយស្រៈ ិ ី ឹ ឺ ើ ាំ ត្រូវដូររាងជាក្បៀស (,) (ការចេះវាក្យសព្ទ)

| | | | | |
|---|---|---|---|---|
| ១. |  | ប៊ីអ | ឆៃយ៉ាំ | ចាប៉ី |
| ២. |  | ហ៊ឹហា | ប៊ីអ | ភាស៊ី |
| ៣. |  | ញ៉ាំ | ញ៉ាំញ៉ើ | រ៉ាំរ៉ៃ |
| ៤. |  | ស៊ាំ | ស៊ី | ឆៃយ៉ាំ |
| ៥. |  | រ៉ាំរ៉ៃ | ភាស៊ី | ប៉ី |
| ៦. |  | កៅស៊ូ | ហ៊ឹហា | ស៊ាំ |

ពិន្ទុ
| |
|---|
| ៦ |

៤.ច៖ សិស្សអាចអានយល់ពាក្យ ឃ្លា ល្បះ ខ្លី ដែលប្រើមូសិកទន្ត(៉) និងត្រីស័ព្ទ(៊) (ការអានដើម្បីយល់)

| | | |
|---|---|---|
| ១. | ចៅម៉ៅចេះយំង៉ាៗ។ | ____ |
| ២. | មីញ៉ាំនារី។ | ____ |
| ៣. | តាប៉ូកេះចាប៉ី។ | ____ |
| ៤. | តាឈ៉ុំឈឺរ៉ាំរ៉ៃ។ | ____ |
| ៥. | វ៉ារចៅវ៉ាចេះ។ | ____ |
| ៦. | ទីនេះអ៊ូអរ។ | ____ |

ពិន្ទុ
| |
|---|
| ៦ |

ពិន្ទុសរុប
| |
|---|
| ៣៦ |

### ការប្រើលទ្ធផលតេស្ត – សំណួរមួយចំនួនដែលត្រូវឆ្លើយ 91

**សំណួរទី១:** សន្មតថាសិស្ស១០នាក់បំពេញចម្លើយស្ទើរតែត្រូវទាំងអស់នៅក្នុងផ្នែក ៤ង ប៉ុន្តែមិនអាចឆ្លើយសំណួរក្នុងផ្នែក ៤ច តើអ្នកនឹងសន្និដ្ឋានដូចម្តេច?

**សំណួរទី២:** សូមផ្តល់នូវសកម្មភាពល្អៗមួយចំនួនដែលអាចយកមកបង្រៀនស្តង់ដានេះឡើងវិញ ។ តើសកម្មភាពគំរូទាំងនេះមាននៅក្នុងទំព័រទីប៉ុន្មាន ?

**សំណួរទី៣:** តើមានសម្ភារល្អៗអ្វីខ្លះដែលអាចយកមកប្រើប្រាស់ក្នុងការបង្រៀនឡើងវិញបាន?

*សូមសរសេរចម្លើយរបស់អ្នកក្នុងចន្លោះដែលបានផ្តល់ខាងក្រោម៖*

សំណួរទី១:

សំណួរទី២:

សំណួរទី៣:

# ឯកសារចែក ៣.៥.៥ : បញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម

ឈ្មោះសិស្ស: ________________________________ ថ្នាក់: _____________

ឈ្មោះគ្រូ: ____________________________ ឆមាស: _____________

| ល.រ | ឈ្មោះសិស្ស (A) | តេស្តបានធ្វើ (√) តេស្ត ១-៩ (សំណេរ); ០១=តេស្តផ្ទាល់មាត់ ១; ០២= តេស្តផ្ទាល់មាត់២ (B) | | | | | | | | | | | កម្រិតស្តង់ដាដែលមិនយល់ (ធ្វើបញ្ជីកម្រិតស្តង់ដា: ១ក, ១ខ ..។ល។) (C) | វិធានការឆ្លើយតបរហ័ស (√) (D) | | | | | | ការវាយតម្លៃ EGRA ចុងក្រោយ (E) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ០១ | ០២ | | ប្រជុំមាតាបិតា | ល្បែងក្នុង បណ្ណាល័យ | សិស្សជួយសិស្ស | មាតាបិតាជួយបង្រៀន | ល្បែងសុសហ្វែរ | ផ្សេងៗទៀត (សូមបញ្ជាក់) | ខ្សោយ (P) មធ្យម (S) ល្អ (G) |
| ១ | | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១២ | | | | | | | | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | | | | | | | | |
| ១៦ | | | | | | | | | | | | | | | | | | | | |
| ១៧ | | | | | | | | | | | | | | | | | | | | |
| ១៨ | | | | | | | | | | | | | | | | | | | | |
| ១៩ | | | | | | | | | | | | | | | | | | | | |
| ២០ | | | | | | | | | | | | | | | | | | | | |

## របៀបបំពេញបញ្ជីតាមដានសិស្សដែលមានតម្រូវការរៀនបន្ថែម

1. បញ្ជីនេះត្រូវប្រើប្រាស់សម្រាប់កត់ត្រាសិស្សដែលជួបការលំបាកក្នុងការអានផ្អែកលើលទ្ធផលនៃតេស្តវាយតម្លៃ ។ បញ្ជីនេះមិនគួរប្រើប្រាស់សម្រាប់សិស្សទាំងអស់នៅក្នុងថ្នាក់នោះទេ ។
2. សិស្សទាំងឡាយណាដែលទទួលបានពិន្ទុតិចជាង៥០% លើកម្រិតស្តង់ដារ (ឧទាហរណ៍ ១ក, ១ខ ។ល។) នៃតេស្តវាយតម្លៃ គឺជាគោលដៅត្រូវរៀបចំអន្តរាគមន៍ដើម្បីជួយពួកគេឱ្យបានចេះ ។
3. សិស្សទាំងឡាយណាដែលស្ថិតក្នុងលក្ខណៈវិនិច្ឆ័យដូចខាងលើត្រូវកត់ឈ្មោះចូលក្នុងបញ្ជីនេះ (ក្ឡោន A) ។
4. សិស្សទាំងឡាយណាដែលមានឈ្មោះក្នុងបញ្ជី ត្រូវបញ្ជាក់ថាពួកគេបានធ្វើតេស្តមួយណា (ឧទាហរណ៍ តេស្តសម្រាប់ដំណាក់កាលទី១, តេស្តសម្រាប់ដំណាក់កាលទី២ ។ល។) គ្រូត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីតាមដានសិស្ស នៅពេលចាប់ផ្តើមធ្វើ តេស្តដំណាក់កាលបន្ទាប់ (ក្ឡោន B) ។
5. គ្រូត្រូវបញ្ជាក់អំពីកម្រិតស្តង់ដារដែលសិស្សជួបការលំបាកនៅក្នុងក្ឡោន (C) ។
6. គ្រូត្រូវបំពេញវិធានការឆ្លើយតបចំពោះសិស្សដែលជួបការលំបាកក្នុងការអានក្នុងក្ឡោន (D) ។ សកម្មភាពនេះគួរតែសម្របសម្រួលជាមួយនាយកសាលា មាតាបិតា បណ្ណារក្ស និងអ្នកពាក់ព័ន្ធដទៃទៀត។
7. ត្រូវធានាដើម្បីបង្ហាញពីពិន្ទុចុងក្រោយ នៃការធ្វើតេស្ត EGRA (បើមានការធ្វើតេស្តនៅសាលា) ក្នុងជួរឈរ E

# បណ្ណពិន្ទុសិស្សសម្រាប់សិស្សដែលមានតម្រូវការរៀនបន្ថែម

*ព្រះរាជាណាចក្រកម្ពុជា*

*ជាតិ សាសនា ព្រះមហាក្សត្រ*

## បណ្ណពិន្ទុសិស្ស

## សម្រាប់សិស្សថ្នាក់ទី១

*ឈ្មោះសិស្ស:* ____________________

*ថ្នាក់:* ________

*សាលាបឋមសិក្សា:*____________________

*ស្រុក:* ____________ *ខេត្ត :* __________

*ឈ្មោះគ្រូ :* ____________________

*ខែ :* ____________ *ឆ្នាំ :* ____________

*ហត្ថលេខាគ្រូ :* ____________________

*សូមជួយកូនរបស់អ្នកក្នុងការរៀនអាននៅផ្ទះដោយឱ្យពួកគេ*

*ហ្វឹកហាត់ល្បែងសិក្សា និងលំហាត់ផ្សេងៗដែលបានស្នើ*

*ក្នុងបញ្ជីបណ្ណពិន្ទុនេះ*

*ឈ្មោះប្រធានបទអំណាន:* ____________________

____________________

*មេរៀនក្នុងសៀវភៅសិក្សាគោល:* ____________________

*ពិន្ទុក្នុងតេស្តដំណាក់កាល:* ________

*ចំណុចដែលកូនរបស់លោកអ្នកជួបការលំបាក:*

____________________

____________________

____________________

____________________

*អ្វីដែលអ្នកអាចធ្វើបាន:*

☐ *មកបណ្ណាល័យដើម្បីសុំខ្ចីល្បែងសិក្សាសម្រាប់កូនអ្នក។ល្បែងសិក្សាឬសៀវភៅដែលអ្នកត្រូវខ្ចីមាន :*

____________________

____________________

☐ ដំឡើងសុសវែរល្បែងសិក្សាចល័តក្នុងទូរស័ព្ទទំនើបបើសិនជាអ្នកមាន ។ បើអ្នកចាប់អារម្មណ៍សូមទាក់ទងគ្រូបង្វឹកអំណានតាមរយៈ:

ទូរស័ព្ទលេខ:____________________